# ជំពូកទី ១៤

# សុវត្ថិភាពសាលារៀន និងការគ្រប់គ្រងវិបត្តិ

## គោលបំណងមេរៀន

អ្នកសិក្សានឹងអាចយល់ និងពន្យល់អំពីៈ
- បញ្ញត្តិសុវត្ថិភាពក៏ដូចជាទ្រឹស្តី និងវិធីសាស្ត្រគ្រប់គ្រងវិបត្តិ
- ស្ថានភាពបច្ចុប្បន្ន និងប្រភេទគ្រោះថ្នាក់ទាក់ទងនឹងកុមារ
- បញ្ញត្តិ និងវិធានការសម្រាប់សុវត្ថិភាពសាលារៀន (ឧទាហរណ៍ សុវត្ថិភាពជីវិតប្រចាំថ្ងៃ និងសុវត្ថិភាពចរាចរណ៍) ដែលគួរអនុវត្តនាពេលអនាគត

ជំពូកនេះពន្យល់បកស្រាយអំពីបញ្ញត្តិមូលដ្ឋាន និងវិធានការសម្រាប់សុវត្ថិភាពសាលារៀន។ មុនដំបូងបង្អស់យើងនឹងលើកអំពីសេចក្តីសង្ខេបនៃបញ្ញត្តិសុវត្ថិភាព ចរិតលក្ខណៈផ្លូវចិត្ត និងរាងកាយរបស់កុមារ និងប្រភេទគ្រោះថ្នាក់។ បន្ទាប់មកនឹងមានការពន្យល់បន្ថែមអំពីស្ថានភាពបច្ចុប្បន្ននៃសុវត្ថិភាពចរាចរណ៍និងតម្រូវការសម្រាប់ការអប់រំអំពីសុវត្ថិភាពចរាចរណ៍នៅប្រទេសកម្ពុជា និងបញ្ញត្តិជាមូលដ្ឋាននៃការគ្រប់គ្រងសុវត្ថិភាព និងការអប់រំសុវត្ថិភាពនៅតាមសាលារៀនដែលនឹងត្រូវអនុវត្តនាពេលអនាគត។

## ១ បញ្ញត្តិនៃសុវត្ថិភាព និងគ្រោះថ្នាក់

ដំបូង យើងនឹងលើកពីការពន្យល់អំពីគំនិតជាមូលដ្ឋាននៃសុវត្ថិភាព និងគ្រោះថ្នាក់។[1]

### ១.១. បញ្ញត្តិនៃសុវត្ថិភាព

សុវត្ថិភាពសំដៅលើ «លក្ខខណ្ឌមួយដែលជីវិត និងទ្រព្យសម្បត្តិរបស់មនុស្សត្រូវបានការពារពីការប្រឈមមុខនឹងគ្រោះធម្មជាតិ ឬគ្រោះថ្នាក់ណាមួយនៅក្នុងជីវិតប្រចាំថ្ងៃ» ចំណែកឯង «កត្តា ឬលក្ខខណ្ឌដែលអាចធ្វើឱ្យអន្តរាយដល់សុវត្ថិភាពរបស់មនុស្ស» ហៅថា **គ្រោះថ្នាក់ (danger or hazard)**។ វត្ថុមួយដែលអាចវាយតម្លៃដោយប្រូបាប៊ីលីតេថាជាផលិតផលបង្កអន្តរាយធ្ងន់ធ្ងរ (ទំហំនៃគ្រោះថ្នាក់ និងការខូចខាត) និងប្រូបាប៊ីលីតេនៃការបង្កគ្រោះថ្នាក់ហៅថា **ហានិភ័យ (risk)** (សូមមើលអត្ថបទដកស្រង់ ១៤.១៖ គំរូហានិភ័យគ្រោះថ្នាក់)។ រឿងមួយដែលមិនអាចវាយតម្លៃបានដោយប្រូបាប៊ីលីតេគឺជា**ភាពមិនប្រាកដ (uncertainty)** ដែលខុសពីហានិភ័យ។ ស្ថានភាពមួយដែលហានិភ័យមួយបានបណ្តាលឱ្យខូចខាតអ្វីមួយដល់អាយុជីវិត ឬទ្រព្យសម្បត្តិរបស់មនុស្សហៅថា **គ្រោះថ្នាក់ (accident)** ចំណែកឯការខូចខាតផ្នែករាងកាយមនុស្សដែលបណ្តាលមកពីគ្រោះថ្នាក់នេះហៅថា **របួស (injury)**។

សម្រាប់មនុស្សដែលបាននិងកំពុងឆ្លងកាត់ការអភិវឌ្ឍក្នុងកម្រិតជាក់លាក់មួយ គឺងាយស្រួលចៀសផុតពី «**គ្រោះថ្នាក់ដែលអាចមើលឃើញ (គ្រោះថ្នាក់ជាក់ស្តែង (explicit danger))**» ប៉ុន្តែពិបាកចៀសវាង «**គ្រោះថ្នាក់មើលមិនឃើញ (គ្រោះថ្នាក់កំបាំង) (invisible danger (latent danger)**» ដែលតែងតែបង្កឱ្យមានគ្រោះថ្នាក់នានា។ វិធានការជាមូលដ្ឋានដើម្បីការពារគ្រោះថ្នាក់គឺការរកឱ្យឃើញ និងការលុបបំបាត់ពីគ្រោះថ្នាក់នោះមុនពេលវាកើតឡើង។

**អត្ថបទដកស្រង់ ១៤.១៖ គំរូហានិភ័យនៃគ្រោះថ្នាក់**

*ទ្រឹស្តីសុវត្ថិភាពមូលដ្ឋានជាច្រើនត្រូវគេបានបង្កើតចេញពីទស្សនៈនៃការបង្ការគ្រោះថ្នាក់ដើម្បីសម្រេចបាននូវសុវត្ថិភាព។ គំរូហានិភ័យនៃគ្រោះថ្នាក់ (hazard risk model) ដែលជាទ្រឹស្តីមួយក្នុងចំណោមទ្រឹស្តីជាច្រើនត្រូវបានពន្យល់នៅក្នុងជំពូកនេះ។*

*គំរូហានិភ័យនៃគ្រោះថ្នាក់គឺជាទ្រឹស្តីស្តីពីសុវត្ថិភាពដែលនាពេលថ្មីៗនេះបានក្លាយជារឿងសំខាន់នៅក្នុងវិស័យសុវត្ថិភាពវិស្វកម្មក៏ដូចជាសុវត្ថិភាព និងសុខភាពការងារ។[1] ទ្រឹស្តីនេះជាមូលដ្ឋានបែងចែកពីរបៀបនៃគ្រោះថ្នាក់ដែលអាចនាំឱ្យមានការកើតឡើងនៃអន្តរាយ (ការខូចខាតដែលបានកើតឡើងពិត) ទៅជាគ្រោះថ្នាក់ និងហានិភ័យ។ វិធីសាស្រ្តក្នុងការប៉ាន់ប្រមាណហានិភ័យមានភាពខុសប្លែកគ្នាទៅតាមវិស័យ និងការអប់រំហើយនិយមន័យខាងក្រោមនេះត្រូវបានអនុម័តសម្រាប់ការការពារគ្រោះថ្នាក់នៅក្នុងវិធាននៃការគ្រប់គ្រងវិបត្តិនៅសាលាមត្តេយ្យ/កន្លែងអប់រំផ្សេងៗ។*

***ហានិភ័យ = ភាពធ្ងន់ធ្ងរនៃគ្រោះថ្នាក់ x ប្រូបាប៊ីលីតេនៃការកើតឡើងនៃការខូចខាតដែលបណ្តាលមកពីគ្រោះថ្នាក់***

*ទោះបីជាគ្រោះថ្នាក់អាចមាន ហើយវាអាចធ្ងន់ធ្ងរប៉ុណ្ណាក៏ដោយ បើប្រូបាប៊ីលីតេនៃគ្រោះថ្នាក់ដែលបង្កគ្រោះថ្នាក់ដល់មនុស្សគឺសូន្យ ឬជិតស្មើសូន្យនោះហានិភ័យក៏នឹងសូន្យ ឬជិតស្មើសូន្យដែរ។*

*ឧទាហរណ៍ កត្តាបង្កគ្រោះថ្នាក់រួមមាន កង់ និងសម្ភារៈនៅកន្លែងសួនកំសាន្ត។ ទាំងនេះគឺជាកត្តាបង្កគ្រោះថ្នាក់ដែលអាចបង្កឱ្យមានការប៉ះទង្គិច ជំពប់ដួល និងធ្លាក់។ ដើម្បីបង្ការគ្រោះថ្នាក់ទាំងនេះ **ទស្សនៈនៃការកែលម្អបរិស្ថាន**គឺមានសារៈសំខាន់ណាស់ដូចជា ការលុបបំបាត់កត្តាបង្កគ្រោះថ្នាក់នានា និងការចាត់វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីការពារកុមារពីគ្រោះថ្នាក់ទាំងនោះ (ឧទាហរណ៍ ការបិទទ្រនាប់ទន់ៗទៅនឹងជ្រុងគុ)។*

### ១.២. គ្រោះមហន្តរាយ និងគ្រោះថ្នាក់

**គ្រោះមហន្តរាយ (Disaster)** សំដៅលើការកើតឡើងនៃរបួស ឬការខូចខាតខ្លះដល់ជីវិត រាងកាយ ឬទ្រព្យសម្បត្តិរបស់មនុស្សដែលបណ្តាលមកពីគ្រោះថ្នាក់មួយចំនួន មកពីបាតុភូតធម្មជាតិ ឬកត្តាមនុស្ស។ គ្រោះមហន្តរាយអាចបែងចែកជា**គ្រោះមហន្តរាយធម្មជាតិ** (ឧទាហរណ៍ គ្រោះមហន្តរាយ ឧតុនិយម និងការរញ្ជួយដី) និង**គ្រោះមហន្តរាយដែលបង្កើតដោយមនុស្ស** (ឧទាហរណ៍ គ្រោះថ្នាក់ជីវិត គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ឧស្សាហកម្ម ការខូចខាតផ្នែកព្រហ្មទណ្ឌ និងវិនាសកម្មសង្គ្រាមដែលបង្កឡើងនៅក្នុងជីវិតប្រចាំថ្ងៃ)។ គ្រោះមហន្តរាយដែលបង្កើតដោយមនុស្សភាគច្រើនកើតឡើងដោយគ្រោះថ្នាក់។ គ្រោះថ្នាក់ទាំងនោះអាចត្រូវបានបែងចែកដូចជា **គ្រោះថ្នាក់ចរាចរណ៍ (traffic accidents)** ក្នុងន័យទូលំទូលាយ (ឧទាហរណ៍ រថយន្ត ផ្លូវរថភ្លើង យន្តហោះ និងគ្រោះថ្នាក់តាមសមុទ្រ) និង**គ្រោះថ្នាក់ក្នុងជីវភាព (life accidents)** ដែលបណ្តាលមកពីស្ថានភាពផ្សេងៗនៅក្នុងជីវភាពប្រចាំថ្ងៃរួមមាន នៅសាលារៀន ផ្ទះ និងសហគមន៍ (គ្រោះថ្នាក់ដែលមិននឹកស្មានដល់ដែលកើតឡើងនៅក្នុងជីវិតប្រចាំថ្ងៃរួមមាន ការថប់ដង្ហើម នឹងជំពប់ជើងដួល/ធ្លាក់)។ គ្រោះថ្នាក់ក្នុងជីវភាពដែលត្រូវប្រឈមមុខនៅតាមសាលារៀនរួមមាន ការធ្លាក់ពីជណ្តើរ និងឧបករណ៍សួនកុមារដែលទ្រុឌទ្រោមអាចកើតមានឡើងសូម្បីតែពេលចេញលេងក៏ដោយ (សូមមើលចំណុច ៦. សុវត្ថិភាពសាលារៀននៃជំពូកទី ១៤ នេះ)។

## ② លក្ខណៈនៃគ្រោះថ្នាក់ទាក់ទងនឹងកុមារផ្អែកលើទស្សនៈនៃដំណាក់កាលអភិវឌ្ឍន៍

តើគ្រោះថ្នាក់ និងរបួសប្រភេទណាខ្លះដែលអាចកើតមានតាំងពីក្មេងរហូតដល់វ័យជំទង់? ផ្នែកនេះពន្យល់អំពីប្រភេទគ្រោះថ្នាក់ និងរបួសដែលអាចកើតមានឡើងតាំងពីវ័យកុមាររហូតដល់វ័យជំទង់ព្រមទាំងកត្តានៅពីក្រោយឧបទ្វវហេតុទាំងនោះ។[2] ដោយសារតែការលូតលាស់ និងការអភិវឌ្ឍចិត្ត និងរាងកាយមិនទាន់ពេញវ័យនៅក្នុងរយៈពេលទាំងនេះ ដូច្នេះចាំបាច់ត្រូវធ្វើឱ្យពួកគេយល់កាន់តែស៊ីជម្រៅអំពីការប្រព្រឹត្តិទៅប្រកបដោយសុវត្ថិភាពខណៈពេលធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសុវត្ថិភាពនៃបរិស្ថានជុំវិញរបស់ពួកគេ។

## ២.១. លក្ខណៈនៃចិត្ត និងរាងកាយ និងឥរិយាបថអំឡុងពេលបឋមវ័យ

បឋមវ័យ/វ័យកុមារភាពដំបូងគឺជារយៈពេលដែលចិត្ត និងរាងកាយលូតលាស់ និងអភិវឌ្ឍយ៉ាងខ្លាំង។ វាក៏ជារយៈពេលមួយដែលសមត្ថភាពក្នុងការទំនាក់ទំនងជាមួយអ្នកដទៃមានការរីកចម្រើន។ លក្ខណៈរាងកាយសំខាន់ៗរបស់កុមារតូចមានដូចខាងក្រោម៖

i. បឋមវ័យគឺជារយៈពេលដែលគេមើលឃើញការលូតលាស់រាងកាយថេរ។
ii. នេះគឺជារយៈពេលដែលមុខងារចក្ខុនិងសោតវិញ្ញាណមានការអភិវឌ្ឍឆ្ពោះទៅដំណាក់កាលបញ្ចប់នៃការលូតលាស់។
iii. ប្រព័ន្ធប្រសាទមានការរីកចម្រើនយ៉ាងខ្លាំងហើយការសម្របសម្រួលរវាងមុខងារជាច្រើនចាប់ផ្តើមអភិវឌ្ឍ។

**ផ្តើមចេញពីទស្សនៈនៃការប្រព្រឹត្តដោយសុវត្ថិភាពចៀសផុតពីគ្រោះថ្នាក់** គេត្រូវគិតពិចារណាលក្ខណៈនៃការលូតលាស់ និងការអភិវឌ្ឍ។ ឧទាហរណ៍ ការអភិវឌ្ឍផ្នែកចក្ខុ និងសោតវិញ្ញាណមិនទាន់បានពេញលេញអាចបណ្តាលឱ្យមានការយល់ដឹងយឺតអំពីគ្រោះថ្នាក់។ ថ្វីត្បិតតែចក្ខុវិញ្ញាណ (គំហើញ) អភិវឌ្ឍខ្លាំងក្នុងវ័យទារកក៏ដោយ ប៉ុន្តែនៅពេលកុមារមានអាយុចាប់ពី ៥-៦កម្រិតគំហើញ នៅត្រឹម ១,0 ឬខ្ពស់ជាងនេះ។ ត្រង់នេះ គេនិយាយថាគំហើញចក្ខុទាំងទ្វេអភិវឌ្ឍពេញលេញនៅអាយុប្រហែលប្រាំឆ្នាំ។

សម្រាប់មុខងារសោតវិញ្ញាណ សមត្ថភាពសំខាន់ដែលទាក់ទងនឹងសុវត្ថិភាពគឺសមត្ថភាពកំណត់មូលដ្ឋានីយកម្មសំឡេង (ទីតាំងនៃប្រភពសំឡេង) ដែលវិវឌ្ឍតាំងពីកុមារនៅតូច។ ដើម្បីចៀសវាងគ្រោះថ្នាក់ដោយការរកឃើញទីតាំងរបស់រថយន្តមួយបានរហ័សគឺចាំបាច់ណាស់ត្រូវកំណត់ទីតាំងប្រភពសំឡេងឱ្យបានច្បាស់។ ទោះបីជាមុខងារចក្ខុនិងសោតវិញ្ញាណបានអភិវឌ្ឍក៏ដោយ ប៉ុន្តែការដឹងពីគ្រោះថ្នាក់នៅមានការយឺតយ៉ាវក្នុងករណីដែលកុមារទាំងនោះទាបនិងពិបាកក្នុងការរកឃើញអ្វីៗនៅជុំវិញខ្លួន ឬក្នុងករណីដែលកុមារទាំងនោះមានបទពិសោធន៍គ្រោះថ្នាក់តិចតួច។ ដោយសារតែការប្រមើលមើលរបស់មនុស្សពេញវ័យតែម្នាក់ឯងអាចរំលងគ្រោះថ្នាក់ ដូច្នេះត្រូវមានការយកចិត្តទុកដាក់គ្រប់គ្រាន់ពីទស្សនៈរបស់កុមារ។

ការអភិវឌ្ឍសមត្ថភាពធ្វើលំហាត់ប្រាណគឺជាកត្តាសំខាន់មួយទៀតដើម្បីចៀសវាងគ្រោះថ្នាក់។ នៅក្នុងការធ្វើលំហាត់ប្រាណ ការសម្របសម្រួលរវាងការសង្កេតនឹងភ្នែកលើគោលដៅ និងចលនារាងកាយគឺជាការសំខាន់។ ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃការសម្របសម្រួលនេះគឺជាលក្ខណៈរបស់កុមារតូច។

## ២.២. ចរិតលក្ខណៈនៃចិត្ត និងរាងកាយ និងឥរិយាបថរបស់សិស្សកម្រិតបឋមសិក្សា

ក្នុងអំឡុងពេលប្រាំមួយឆ្នាំនៃការសិក្សានៅបឋមសិក្សា ការផ្លាស់ប្តូរដ៏សំខាន់ៗត្រូវបានសង្កេតឃើញការលូតលាស់និងការអភិវឌ្ឍ។ ដោយឡែក កុមារដែលមានអាយុពី ១០-១២ឆ្នាំ កំពុងស្ថិតក្នុងដំណាក់កាលលូតលាស់លឿន និងបង្ហាញពីសន្ទុះនៃការលូតលាស់ជាពិសេសការលូតកម្ពស់។ នៅក្នុងអំឡុងពេលនេះសមត្ថភាពធ្វើលំហាត់ប្រាណក៏រីកចម្រើនដែលជាមូលដ្ឋានគ្រឹះនៃរាងកាយដែលត្រូវការដើម្បីប្រកបដោយសុវត្ថិភាព។

ទោះជាយ៉ាងណាក៏ដោយ តាមទស្សនៈនៃសុវត្ថិភាពការផ្លាស់ប្តូរផ្លូវចិត្ត/សង្គម ឬឥរិយាបថ គឺជាចរិតលក្ខណៈដែលសំខាន់ជាងការលូតលាស់រាងកាយ (**តារាងទី ១៤.១**)។ សិស្សសាលាបឋមសិក្សាបានពង្រីកសកម្មភាពរបស់ពួកគេយ៉ាងច្រើនដែលជាភាពខុសប្លែកគ្នាតាំងពីកុមារភាពដែលនៅពេលនោះពួកគេបានរស់នៅក្រោមការការពាររបស់ឪពុកម្តាយ។ ហេតុនេះហើយលទ្ធភាពនៃការជួបប្រទះនូវគ្រោះថ្នាក់ក៏មានច្រើនដែលតម្រូវឱ្យពួកគេជ្រើសរើសឥរិយាបថណាដែលមានសុវត្ថិភាពដោយខ្លួនឯង។

ជាពិសេស នៅពេលរៀនដល់ថ្នាក់កាន់តែខ្ពស់ ភាពអសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយបញ្ហាផ្លូវចិត្តអាចបណ្តាលឱ្យមានស្ថានភាពមិនស្ថិតស្ថេរដែលអាចនាំឱ្យមានគ្រោះថ្នាក់ធំ/គ្រោះមហន្តរាយ។ ដូច្នេះវាពិតជាមានសារៈសំខាន់ណាស់ដែលត្រូវមានការណែនាំ ការគ្រប់គ្រង និងការយកចិត្តទុកដាក់ពីមនុស្សធំដែលនៅជុំវិញពួកគេ។

លើសពីនេះទៅទៀត ទម្លាប់នៃការរស់នៅជុំវិញការបរិភោគ ការធ្វើលំហាត់ប្រាណ និងការសម្រាកអាចគ្មានភាពទៀងទាត់ទេនៅពេលរៀនដល់ថ្នាក់កាន់តែខ្ពស់។ បន្ទាប់ពីត្រលប់មកដល់ផ្ទះវិញនៅថ្ងៃសិក្សាធម្មតា សិស្សបឋមសិក្សាចំណាយពេលច្រើនមើលទូរទស្សន៍ ហ្គេម និងទូរស័ព្ទទំនើប (ស្មាតហ្វូន) លើកលែងតែពេលធ្វើកិច្ចការសាលា និងកិច្ចការផ្ទះរបស់ពួកគេ។ បែបបទនៃការរស់នៅបែបនេះអាចប៉ះពាល់ដល់របៀបរស់នៅទៀងទាត់របស់កុមារ នឹងពាក់ព័ន្ធនឹងហានិភ័យដែលបណ្ដាលឱ្យមានផលប៉ះពាល់ដល់សុខភាពរបស់ពួកគេ (សូមមើលជំពូកទី ៥)។ ទោះបីជាវាគ្មានផលប៉ះពាល់ផ្ទាល់ទៅលើសុវត្ថិភាពជីវិតក៏ដោយ វាអាចបណ្ដាលឱ្យមានការរំខាននៅក្នុងជីវិតប្រចាំថ្ងៃ ឬនាំឱ្យមានឥរិយាបថគ្រោះថ្នាក់ដែលត្រូវបានរៀបរាប់នៅពេលក្រោយ។ ដូច្នេះគេមិនអាចមិនអើពើអំពីទស្សនៈនៃការអប់រំសុវត្ថិភាពទេ (សូមមើលចំណុច ១.២. អំពីគ្រោះថ្នាក់ក្នុងជីវភាព នៃជំពូកទី ១៤ នេះ)។

**តារាងទី ១៤.១៖ លក្ខណៈចិត្តសាស្ត្រ សង្គម និងអាកប្បកិរិយារបស់សិស្សកម្រិតបឋមសិក្សា**

| អាយុចូលរៀន | លក្ខណៈចិត្តសង្គម | លក្ខណៈឥរិយាបថ |
|---|---|---|
| ថ្នាក់ទាប | • អាចយល់ពីផលវិបាកនៃឥរិយាបថរបស់ពួកគេ។<br>• មានគំនិតផ្ទាល់ខ្លួនហើយពេលខ្លះប្រឆាំងនឹងឪពុកម្ដាយរបស់ពួកគេ។ | • ឥរិយាបថឆេវឆាវថយចុះ<br>• សកម្មភាពក្នុងក្រុមដែលមានតែកុមារកើនឡើង<br>• បង្ហាញឥរិយាបថសមរម្យដោយយល់ពីផលវិបាកនៃឥរិយាបថរបស់ពួកគេ |
| ថ្នាក់ខ្ពស់ | បញ្ហាផ្លូវចិត្តកើនឡើងដូចជា អារម្មណ៍តានតឹង និងមិនអាចគ្រប់គ្រងអារម្មណ៍របស់ពួកគេ។ | • មានទំនោរផ្ដល់សារៈសំខាន់កាន់តែច្រើនចំពោះទំនាក់ទំនងជាមួយមិត្តភក្ដិជាងជាមួយមនុស្សធំ (គ្រូ ឪពុកម្ដាយ)<br>• អសមត្ថភាពក្នុងការដោះស្រាយបញ្ហាឱ្យបានសមស្របអាចបណ្ដាលឱ្យមានស្ថានភាពផ្លូវចិត្តមិនស្ថិតស្ថេរនិងនាំឱ្យមានអំពើហិង្សា ឬការបំផ្លាញរបស់របរ<br>• បាត់បង់ម្ចាស់ការលើខ្លួនឯង<br>• បាត់បង់របៀបរស់នៅជាមូលដ្ឋាន<br>• ចំណាយពេលច្រើនមើលទូរទស្សន៍ ហ្គេម និងស្មាតហ្វូន បន្ទាប់ពីត្រឡប់មកផ្ទះវិញ |

### ២.២.១. បញ្ហាប្រឈមក្នុងការអប់រំសុវត្ថិភាពដល់សិស្សកម្រិតបឋមសិក្សា

ការអភិវឌ្ឍផ្លូវចិត្តទាក់ទងនឹងបុព្វហេតុនៃឥរិយាបថ និងការព្យាករណ៍ពីផលវិបាករបស់វាគឺជាកត្តាសំខាន់មួយពីទស្សនៈនៃការព្យាករណ៍ និងការចៀសវាងពីគ្រោះថ្នាក់។ កុមារនៅបឋមសិក្សាងាយយល់អំពីទំនាក់ទំនង លក្ខណៈបែបនេះពីថ្នាក់ក្រោមដែលអនុញ្ញាតឱ្យមានការអប់រំពីសុវត្ថិភាពនៅបឋមសិក្សាប្រកបដោយប្រសិទ្ធភាព។ នៅបឋមសិក្សា សិស្សតម្រូវឱ្យចាប់ផ្ដើមជាមួយនឹងការបង្កើតការយល់ដឹងអំពីគ្រោះថ្នាក់នៅជុំវិញពួកគេតាមរយៈបទពិសោធន៍ និងបង្កើនចំណេះដឹងបន្តិចម្ដងៗ អំពីគ្រោះថ្នាក់ និងគ្រោះមហន្តរាយនានា។ ជាពិសេស នៅថ្នាក់ខ្ពស់គឺមានប្រសិទ្ធភាពក្នុងការប្រើព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយធំៗ (ទូរទស្សន៍ វិទ្យុ និងកាសែត/ទស្សនាវដ្ដី) និងអ៊ីនធឺណែតដើម្បីជួយសិស្សឱ្យយល់ និងពិចារណាអំពីសុវត្ថិភាពក្នុងការអប់រំពីសុវត្ថិភាព។

សិស្សសាលាបឋមសិក្សាស្ថិតក្នុងដំណាក់កាលមួយដែលពួកគេមាន**សម្បជញ្ញៈបទដ្ឋាន**ខ្ពស់ ហើយមានឆន្ទៈទទួលយកការណែនាំពីមនុស្សធំ។ រយៈពេលនេះត្រូវបានចាត់ទុកថា សមស្របសម្រាប់ការអប់រំសុវត្ថិភាព។ ទោះជាយ៉ាងណាក៏ដោយ ក្រៅពីផ្តល់ការអប់រំអំពីសុវត្ថិភាពដល់កុមារ វាក៏មានសារៈសំខាន់ផងដែរសម្រាប់មនុស្សធំដែលត្រូវមានឥរិយាបថសុវត្ថិភាពជាគំរូ។ វាគឺជាមូលដ្ឋាននៃការអប់រំសុវត្ថិភាពសម្រាប់មនុស្សពេញវ័យដើម្បីធ្វើជាគំរូជាមុនសិនដូចជាការអនុលោមតាមបទបញ្ញត្តិនានា។ លើសពីនេះទៅទៀត វាក៏មានសារៈសំខាន់ផងដែរក្នុងការបន្ថែមបន្តិចម្តងៗលើកការពិចារណាពីសុវត្ថិភាពរបស់អ្នកដទៃ ជាពិសេសសុវត្ថិភាពរបស់សមាជិកគ្រួសារ យុវជន និងមនុស្សចាស់ទៅក្នុងខ្លឹមសារនៃការបង្រៀន។

## ២.៣. ចរិកលក្ខណៈនៃចិត្ត និងរាងកាយ និងឥរិយាបថរបស់សិស្សកម្រិតអនុវិទ្យាល័យ

ការឈានដល់វ័យពេញវ័យនៅក្នុងរយៈពេលនេះ សិស្សព្យាយាមមានភាពឯករាជ្យខាងផ្លូវចិត្តពីឪពុកម្តាយ ឬប្រឆាំងនឹងឪពុកម្តាយ និងសាលារៀនញឹកញាប់ជាងពេលមុន។ នៅអនុវិទ្យាល័យ ចំនួនករណីនៃការគំរាមកំហែង (bullying) និងអំពើហិង្សាមានទំហំធំជាងនៅបឋមសិក្សា និងមធ្យមសិក្សា។ នេះបង្ហាញថា វាក៏ជារយៈពេលដែលអាចមានឥរិយាបថគ្រោះថ្នាក់ដូចជា ការកើនឡើងឥរិយាបថបង្កហេតុ (សូមមើលជំពូកទី ១១)។

**ការធ្លាក់ចុះនៃសម្បជញ្ញៈបទដ្ឋាន**ត្រូវបានលើកឡើងថាជាកត្តាមួយសម្រាប់ឥរិយាបថគ្រោះថ្នាក់។ សិស្សនៅអនុវិទ្យាល័យត្រូវបានបណ្តោយឱ្យប្រព្រឹត្តអំពើនានាប្រឆាំងនឹងច្បាប់សង្គម។ ឧទាហរណ៍ បែបនេះរួមមាន ការឆ្លងកាត់ផ្លូវដោយមិនអើពើភ្លើងសញ្ញាចរាចរណ៍ និងការប្រើទូរស័ព្ទដៃ/ស្មាតហ្វូនពេលដើរ/កំពុងដើរ។ ការធ្លាក់ចុះនៃការគោរពតាមបទដ្ឋានសង្គមមិននាំឱ្យមានបញ្ហាឥរិយាបថដោយផ្ទាល់ទេ ប៉ុន្តែឧទាហរណ៍ នៅពេលវាមានទំនាក់ទំនងជាមួយការប្រើប្រាស់គ្រឿងញៀនវារួមចំណែកបានជាកត្តាសំខាន់មួយ។

ភាពងាយទទួល**សម្ពាធពីមិត្តភក្តិ**ក៏ជាលក្ខណៈនៃវ័យនេះដែរ។ សិស្សចាប់ផ្តើមបង្ហាញនូវនិន្នាការខ្លាចក្នុងការដេញចេញពីក្រុម ហើយដូច្នេះហ៊ានធ្វើរឿងគ្រោះថ្នាក់ដើម្បីផ្គាប់ចិត្តពួកម៉ាករបស់ពួកគេ និងបង្កើនអារម្មណ៍ថាជាកម្មសិទ្ធិរបស់ក្រុមមិត្តភក្តិ។

### ២.៣.១. បញ្ហាប្រឈមនៃការអប់រំសុវត្ថិភាពរបស់សិស្សកម្រិតវិទ្យាល័យ

ទំនោរក្នុងការព្យាយាមភ្ជាប់ទៅនឹង**ឥរិយាបថគ្រោះថ្នាក់នេះ**មិនកំណត់ចំពោះតែកុមារណាម្នាក់ជាពិសេសនោះទេ។ ផ្ទុយទៅវិញ គេអាចឃើញទំនោរនេះនៅក្នុងដំណើរការអភិវឌ្ឍធម្មតារបស់ក្រុមមនុស្សវ័យក្មេង និងដើរតួនាទីយ៉ាងសំខាន់សម្រាប់ការលូតលាស់របស់ពួកគេទៅជាមនុស្សពេញវ័យទោះបីជាល្អ ឬអាក្រក់ក៏ដោយ។ ឥរិយាបថគ្រោះថ្នាក់ជាមធ្យោបាយមួយដើម្បីមានឯករាជ្យភាពពីឪពុកម្តាយ ដើម្បីសេពគប់មិត្តភក្តិ។ ផ្ទុយទៅវិញ វាអាចនាំឱ្យមានការធ្លាក់ចុះនៃការគោរពតាមបទដ្ឋានសង្គមដែលតំណាងដោយច្បាប់របស់សាលា។ ទាំងនេះបង្កឱ្យមានឥរិយាបថគ្រោះថ្នាក់ផ្សេងៗ។ គេគិតថា អាកប្បកិរិយាគ្រោះថ្នាក់បំផុតនៅក្នុងរយៈពេលនេះនៅតែជាឥរិយាបថស្វែងរក (ការប៉ុនប៉ង) មានខ្លះៗដែលនាំឱ្យមានឥរិយាបថប្រាសចាក និងឥរិយាបថគ្រោះថ្នាក់ជាបន្តបន្ទាប់។

ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើវាជាឥរិយាបថដែលអាចបំផ្លាញខ្លួនឯង ឬអ្នកដទៃ និងអាចបណ្តាលឱ្យពួកគេស្លាប់ គ្រូបង្រៀនត្រូវប្រាប់សិស្សឱ្យបានត្រឹមត្រូវអំពីសារៈសំខាន់នៃការគោរពជីវិតខ្លួនឯង និងជីវិតរបស់អ្នកដទៃ ព្រមទាំងផលវិបាកនៃឥរិយាបថធ្វេសប្រហែស និងផ្តល់យុត្តិកម្មសម្រាប់ការប្រព្រឹត្តដោយសុវត្ថិភាព។

លើសពីនេះទៅទៀត នៅក្នុងការអប់រំសុវត្ថិភាពសិស្សត្រូវរៀនមិនត្រឹមតែហានិភ័យជាជនរងគ្រោះនៃឧបទ្ទវហេតុ/គ្រោះថ្នាក់ (incident/accident) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរៀនអំពីហានិភ័យដែលអាចបង្កការខូចខាតដល់អ្នកដទៃផងដែរ។ ឧទាហរណ៍ ការជិះកង់ដោយមិនប្រុងប្រយ័ត្ន ឬគ្មានពន្លឺអាចបណ្តាលឱ្យប៉ះទង្គិចជាមួយអ្នកថ្មើរជើងហើយថែមទាំងអាចឆក់យកជីវិតមនុស្សក្នុងករណីអាក្រក់បំផុត។ សូម្បីតែសិស្សវិទ្យាល័យក៏ត្រូវយល់ដឹងឱ្យបានច្បាស់អំពីការទទួលខុសត្រូវរបស់ខ្លួនចំពោះសុវត្ថិភាពចរាចរណ៍ក្នុងនាមជាប្រជាពលរដ្ឋមួយរូប។

## ៣ មូលហេតុនៃរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍ពាក់ព័ន្ធនឹងអនីតិជន

**គ្រោះថ្នាក់ចរាចរណ៍**នៅប្រទេសកម្ពុជាមានភាគរយរងរបួសខ្ពស់បំផុតនៃគ្រោះថ្នាក់ចរាចរណ៍ដោយ ៧១,៨% នៃអ្នកដែលរងរបួសក្នុងរយៈពេល ១២ខែ ចុងក្រោយនេះទាក់ទងនឹងគ្រោះថ្នាក់លើដងផ្លូវ (**តារាងទី ១៤.២**)។ ក្នុងចំណោមរបួសនានាមាន ដួល និងជំពប់ដួលមានចំនួន ៩,៧% បន្ទាប់មកមានពស់ ឬសត្វខាំ ៥,១% អំពើហិង្សា ២,៤% រលាកធ្ងន់ធ្ងរ ១,២% និងការបាញ់កាំភ្លើង ការលង់ទឹកស្លាប់ និងពុលតិចជាង ១%។ មូលហេតុផ្សេងទៀត ឬមិនស្គាល់មានចំនួន ៩,២% នៃរបួស។

ចំពោះ**ការរងរបួសចំពោះអ្នកដែលមានអាយុពី 0-៩ឆ្នាំ** មូលហេតុចម្បងគឺគ្រោះថ្នាក់ចរាចរណ៍ ៤៨,៧% បន្ទាប់មកការធ្លាក់ និងជំពប់ដួល ២២,៥% ពស់ ឬសត្វខាំ ១៣,៥% ការរលាកធ្ងន់ធ្ងរ ២,0% អំពើហិង្សា ១,៥% និងមូលហេតុផ្សេងទៀត ឬមិនស្គាល់មាន ១១,៧%។

ចំពោះ**របួសរបស់អ្នកដែលមានអាយុពី ១0-១៩ឆ្នាំ** មូលហេតុចម្បងគឺគ្រោះថ្នាក់ចរាចរណ៍ ៦៧,៨% បន្ទាប់មកការធ្លាក់ និងជំពប់ជើងដួល ៩,២% ពស់ ឬសត្វខាំ ៥,១% អំពើហិង្សា ៣,៧% រលាកធ្ងន់ធ្ងរ ២,0% និងមូលហេតុផ្សេងទៀត ឬមិនស្គាល់មាន ១២,១%។

**តារាងទី ១៤.២៖ មូលហេតុនៃការរងរបួសតាមអាយុ**

| អាយុ | ប្រភេទនៃគ្រោះថ្នាក់ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | គ្រោះថ្នាក់ចរាចរណ៍ | ការធ្លាក់ពីដើមឈើ/អគារ | ពស់ចឹក ឬសត្វខាំ | អំពើហិង្សា | រលាកធ្ងន់ធ្ងរ | ការបាញ់កាំភ្លើង | ការពុល (សារជាតិគីមី) | ការលង់ទឹកស្លាប់ | ផ្សេងៗ | មិនស្គាល់មូលហេតុ/បាត់ខ្លួន |
| **របួស** | | | | | | | | | | |
| 0-9 | 48.7 | 22.5 | 13.5 | 1.5 | 2.0 | 0.0 | 0.0 | 0.0 | 6.6 | 5.1 |
| 10-19 | 67.8 | 9.2 | 5.1 | 3.7 | 2.0 | 0.0 | 0.0 | 0.0 | 12.1 | 0.0 |
| 20-39 | 79.4 | 6.1 | 3.3 | 2.7 | 1.1 | 0.7 | 0.4 | 0.0 | 6.3 | 0.0 |
| 40-59 | 73.1 | 11.1 | 4.5 | 1.6 | 0.9 | 0.1 | 0.6 | 0.0 | 8.2 | 0.0 |
| 60+ | 60.3 | 13.1 | 6.4 | 1.1 | 0.0 | 0.0 | 0.0 | 0.0 | 17.6 | 1.4 |
| សរុប | 71.8 | 9.7 | 5.1 | 2.4 | 1.2 | 0.3 | 0.3 | 0.0 | 8.6 | 0.6 |

Percentage of the population injured in an accident in the past 12 months by type of accident according to age, Cambodia 2014

ប្រភព៖ Adapted from Reference[4]

## ៤ សុវត្ថិភាពចរាចរណ៍ និងការបង្ការគ្រោះថ្នាក់ចរាចរណ៍

គ្រោះថ្នាក់ចរាចរណ៍គឺជាបញ្ហាដែលយើងទាំងអស់គ្នាអាចជួបប្រទះ។ នៅប្រទេសកម្ពុជា អត្រាមរណភាពដែលជាប់ទាក់ទងនឹងគ្រោះថ្នាក់ចរាចរណ៍កំពុងកើនឡើងជារៀងរាល់ឆ្នាំ (**រូបទី ១៤.១**)។[5] ការស្លាប់ភាគច្រើនទាក់ទងនឹង**ម៉ូតូនិងត្រីចក្រយាន**។ ការបង្ការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍តម្រូវឱ្យមានការបង្កើតច្បាប់ និងបទបញ្ញាពាក់ព័ន្ធ ការបង្កើតបរិយាកាសចរាចរណ៍ប្រកបដោយសុវត្ថិភាព (ពោលគឺការកសាងបណ្ដាញផ្លូវថ្នល់ និងការកែលម្អគុណភាពផ្លូវថ្នល់ដែលមានស្រាប់) ការត្រួតពិនិត្យនិងថែទាំយានយន្ត និងសកម្មភាពអប់រំប្រជាជនតាមរយៈការអប់រំសុវត្ថិភាពចរាចរណ៍។

បញ្ហាប្រឈមនៅកម្ពុជារួមមាន ការយល់ដឹងទាបរបស់អ្នកបើកបរចំពោះសុវត្ថិភាព**អ្នកប្រើប្រាស់ផ្លូវដែលងាយរងគ្រោះ** (ពោលគឺ កុមារ មនុស្សចាស់ និងអ្នកថ្មើរជើង) និងការយល់ដឹងទាបអំពីការអនុលោមតាមច្បាប់ (ពោលគឺការអនុលោមតាមច្បាប់ចរាចរណ៍ ការពាក់មួកសុវត្ថិភាព និងជាពិសេសមិនរំលោភបំពានល្បឿនកំណត់ ឬការបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង)។

ខ្លឹមសារនៃ**ការអប់រំសុវត្ថិភាពចរាចរណ៍** (**តារាងទី ១៤.៣**) នៅក្នុងសាលារៀនរួមមាន ការយល់ដឹងអំពីគ្រោះថ្នាក់នៅកន្លែងកើតហេតុចរាចរណ៍ផ្សេងៗ ព្រមទាំងការសិក្សាពីការដើរដោយសុវត្ថិភាព និងការប្រើប្រាស់កង់ ម៉ូតូនិងម៉ូតូកង់បីប្រកបដោយសុវត្ថិភាព។ លើសពីនេះទៅទៀត វាមានសារៈសំខាន់ណាស់ដែលត្រូវអនុវត្តឥរិយាបថសុវត្ថិភាពតាមរយៈការសិក្សាពីការ**ព្យាករណ៍ និងការចៀសវាងពីគ្រោះថ្នាក់**។ គោលដៅសំខាន់នៃការអប់រំ សុវត្ថិភាពចរាចរណ៍ គឺការប្រព្រឹត្តស្របតាមច្បាប់ចរាចរណ៍ និងមានវិធានការត្រឹមត្រូវដើម្បីការពារដោយខ្លួនឯងនោះគឺ «**ឈប់**» «**មើល**» និង «**ត្រួតពិនិត្យ**»។[6] ទន្ទឹមនឹងនេះដែរ វិធានការទាំងនេះគឺជាមូលដ្ឋានសម្រាប់ការបង្កើត**សង្គមមានសុវត្ថិភាពចរាចរណ៍**។




ប្រភព៖ Created using Reference[5]

**រូបទី ១៤.១៖** អត្រាសស្លាប់បណ្តាលមកពីរបួសចរាចរណ៍តាមដងផ្លូវ (ក្នុងចំណោមប្រជា ជន ១០០ ០០០នាក់)

## **តារាងទី ១៤.៣៖** ខ្លឹមសារនៃការអប់រំ សុវត្ថិភាពចរាចរណ៍

| | |
|---|---|
| i. | ស្វែងយល់ពីគ្រោះថ្នាក់ដែលទាក់ទងនឹងការដើរលើផ្លូវ និងការឆ្លងកាត់ផ្លូវ និងរបៀបប្រព្រឹត្តដោយសុវត្ថិភាព |
| ii. | ការត្រួតពិនិត្យ/ថែទាំកង់ និងរបៀបជិះកង់បានត្រឹមត្រូវ |
| iii. | ស្វែងយល់ពីលក្ខណៈរបស់ម៉ូតូ និងម៉ូតូកង់បី និងការប្រើប្រាស់ប្រកបដោយសុវត្ថិភាព |
| iv. | ស្វែងយល់ពីលក្ខណៈរបស់រថយន្ត និងឥរិយាបថប្រកបដោយសុវត្ថិភាពក្នុងការបើកបររថយន្ត |
| v. | យល់ត្រឹមត្រូវ និងគោរពអនុវត្តតាមតាមច្បាប់ចរាចរណ៍ |
| vi. | ស្វែងយល់ពីកាតព្វកិច្ច និងការទទួលខុសត្រូវរបស់អ្នកបើកបរ រួមទាំងករណីដែល កង់ត្រូវបានប្រើប្រាស់ផងដែរ |
| vii. | ស្វែងយល់ និងយកចិត្តទុកដាក់ពីសុវត្ថិភាពចរាចរណ៍របស់កុមារ មនុស្សចាស់ ជនពិការ អ្នកជំងឺ អ្នករបួស និងអ្នកថ្មើរជើង |
| viii. | ស្វែងយល់ពីសារៈសំខាន់នៃការបង្កើតសង្គមសុវត្ថិភាពចរាចរណ៍ និងការចូលរួម/កិច្ចសហប្រតិបត្តិការយ៉ាងសកម្ម |
| ix. | មុខងាររបស់អង្គការពាក់ព័ន្ធដូចជា ប៉ូលីស និងអ្នកពន្លត់អគ្គីភ័យ |

ប្រភព៖ Created using Reference[6]

**អត្ថបទដកស្រង់ ១៤.២៖ ស្ថានភាពនៃការធ្វើដំណើររបស់សិស្ស និងបញ្ហាប្រឈមនៃការប្រើប្រាស់មួកសុវត្ថិភាព នៅប្រទេសកម្ពុជា**

*នៅប្រទេសកម្ពុជា មធ្យោបាយធ្វើដំណើរភាគច្រើនបំផុតគឺម៉ូតូ។ ម៉ូតូមានចំនួនជាង ៨០% នៃយានយន្តដែលបានចុះបញ្ជីជាផ្លូវការ។ ការស្លាប់ដែលបណ្តាលមកពីគ្រោះថ្នាក់ម៉ូតូមាន ៦៧% ក្នុងចំណោមអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ប្រចាំឆ្នាំ។ លើសពីនេះទៅទៀត ចំនួនអ្នកស្លាប់កំពុងកើនឡើង។ ច្បាប់របស់ប្រទេសកម្ពុជាតម្រូវឱ្យអ្នកបើកបរម៉ូតូពាក់មួកសុវត្ថិភាព ប៉ុន្តែមិនតម្រូវឱ្យអ្នកជិះជាមួយពាក់មួកសុវត្ថិភាពទេ។ ប្រសិនបើទាំងអ្នកបើកបរ និងអ្នករួមដំណើរបានពាក់មួកសុវត្ថិភាព ពួកគេអាចចៀសផុតពីការស្លាប់។ ការការពារគ្រោះថ្នាក់ម៉ូតូគឺជាបញ្ហាប្រឈមដ៏សំខាន់នៅក្នុងការអប់រំអំពីសុវត្ថិភាពចរាចរណ៍របស់ប្រទេសកម្ពុជា។*

*លើសពីនេះទៅទៀត ទោះបីជាច្បាប់អនុញ្ញាតឱ្យមនុស្សដែលមានអាយុចាប់ពី ១៦ឆ្នាំឡើងទៅ អាចបើកបរម៉ូតូបានក៏ដោយ ក៏ច្បាប់នេះមិនត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងទេ។ ឧទាហរណ៍ យើងឃើញសិស្សានុសិស្សដែលរស់នៅឆ្ងាយពីសាលា ហើយពិបាកធ្វើដំណើរដោយថ្មើរជើង ឬជិះកង់ បាននឹងកំពុងបើកម៉ូតូទៅសាលាជារៀងរាល់ថ្ងៃ។ ជារឿយៗគេឃើញសិស្សជិះម៉ូតូមួយគ្រឿងមានគ្នាពីរ ឬបីនាក់ មានពេលខ្លះលើសពីបីនាក់ ហើយពួកគេកម្រពាក់មួកសុវត្ថិភាពណាស់។ នេះគឺជាបញ្ហាប្រឈមក្នុងការចូលរៀន និងសុវត្ថិភាពនៃការធ្វើដំណើរ។*

## ៥ ការបង្ការគ្រោះថ្នាក់ផ្នែកព្រហ្មទណ្ឌ

ជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនគរូបនីយកម្ម និងការប្រើប្រាស់កុំព្យូទ័រ ការបង្ការ**គ្រោះថ្នាក់ផ្នែកព្រហ្មទណ្ឌ**ដូចជា **ការចាប់ពង្រាត់** និង**ការបង្ករបួស** បានក្លាយជាបញ្ហាប្រឈមដ៏សំខាន់មួយសម្រាប់សុវត្ថិភាពសាលារៀន។ ចំនួនករណីគ្រោះថ្នាក់ផ្នែកព្រហ្មទណ្ឌតាមរយៈការប្រើប្រាស់អ៊ីនធឺណែតដែលទាក់ទងនឹងការរីករាលដាលនៃស្មាតហ្វូន និង SNS (បណ្តាញសេវាសង្គម) បានកើនឡើង ហើយការបង្ការគ្រោះថ្នាក់ផ្នែកព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងសិស្សសាលាបានក្លាយជាបញ្ហាប្រឈមសកលដ៏សំខាន់ (សូមមើលអត្ថបទដកស្រង់ ១៤.៣៖ កុមាររស់នៅក្នុងយុគសម័យឌីជីថល)។ ទោះជាយ៉ាងណាក៏ដោយ សាលារៀនតែឯងមិនអាចដោះស្រាយបញ្ហាប្រឈមនេះបានទាំងស្រុងទេគឺសង្គមទាំងមូលរួមគ្នាដោះស្រាយ។

ផ្នែកនេះពន្យល់ពីរបៀបឆ្លើយតបទៅនឹងវត្តមានរបស់មនុស្សដែលគួរឱ្យសង្ស័យដែលសាលារៀននៅកម្ពុជានឹងត្រូវការដោះស្រាយនាពេលអនាគត។[2]

### ៥.១. ប្រព័ន្ធហាងវ៉ែរបង្ការបទឧក្រិដ្ឋ (បរិក្ខារ និងការដំឡើង)

ជាវិធានការបង្ការបទឧក្រិដ្ឋតាមរយៈការប្រើប្រាស់និងការដំឡើងបរិក្ខារ គេនិយាយពីគោលការណ៍នៃ «**ការធានាភាពមើលឃើញ** និង**ការពង្រឹង/ការថែរក្សាដែនសមត្ថកិច្ច**» និង «**ការត្រួតពិនិត្យការចេញចូល**»។ វិធានការទាំងនេះដើម្បីមើលឃើញច្បាស់សព្វគ្រប់ទិសទី (ការធានាភាពមើលឃើញ និងការពង្រឹង/ការថែរក្សាដែនសមត្ថកិច្ច) និងទប់ស្កាត់អ្នកដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋពីការលបលួចចូលទៅក្នុងបរិវេណសាលារៀន និងអគារសិក្សា (ត្រួតពិនិត្យការចេញចូល)។ ដើម្បីសម្រេចបំណងនេះ អ្វីដែលអាចធ្វើបានមុនគេនៅកម្ពុជាគឺការធ្វើរបងព័ទ្ធជុំវិញបរិវេណ និងដាក់សន្តិសុខការពារ។ របងក៏អាចការពារកុំឱ្យសត្វឆ្កែ និងសត្វស្រុកនានាចូលដូចជា ពពែ និងដើម្បីការពារការខូចខាតក្នុងបរិវេណពីការបន្ទោរបង់គ្មានអនាម័យក៏ដូចជាគ្រោះថ្នាក់ដែលបណ្តាលមកពីឆ្កែព្រៃខាំ។

លើសពីនេះទៅទៀត នៅពេលដែលសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចមូលដ្ឋានមានការរីកចម្រើន គេអាចមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធសន្តិសុខបន្ថែមម្តងៗដូចជា ការបំពាក់កាមេរ៉ាសុវត្ថិភាព និងប្រព័ន្ធទូរស័ព្ទ ការបំពាក់ប្រព័ន្ធចាក់សោរស្វ័យប្រវត្តិនៅច្រកទ្វារ និងប្រព័ន្ធប្រកាសអាសន្ន។

ការបំពាក់ឧបករណ៍ទាំងនេះគេមិនរំពឹងថាមានប្រសិទ្ធភាពខ្ពស់ទេ បើគ្មានការគ្រប់គ្រងវិបត្តិតាមប្រព័ន្ធសូហ្វវែរ (Software Aspects) ដែលនឹងនិយាយនៅពេលក្រោយ។ ទោះបីជាមានការបំពាក់មេ៉ាសុវត្ថិភាពក៏ដោយ ប្រសិនបើប្រព័ន្ធត្រួតពិនិត្យអំពើចេតនាមិនគ្រប់គ្រាន់ ឬប្រព័ន្ធជូនដំណឹងខូចធ្វើឱ្យជនសង្ស័យងាយស្រួលលបលួចចូលក្នុងបរិវេណ។ ចូរកត់សម្គាល់ថា ប្រព័ន្ធហាដវែរនឹងមានប្រសិទ្ធភាពលុះត្រាតែប្រព័ន្ធសូហ្វវែរទំនើប។

## ៥.២. ប្រព័ន្ធសូហ្វវែរបង្ការបទឧក្រិដ្ឋ

វាមានសារៈសំខាន់ណាស់ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងវិបត្តិនៅតាមសាលារៀន ហើយបង្កើត និងអនុវត្តវិធានការប្រកបដោយប្រសិទ្ធភាពដោយផ្អែកលើលក្ខណៈជាប្រព័ន្ធ ជាពិសេសបង្កើត និងអនុវត្តសៀវភៅណែនាំគ្រប់គ្រងវិបត្តិ។ ចំណុចដែលត្រូវអនុវត្តមានដូចខាងក្រោម៖

i. បង្កើត**ប្រព័ន្ធគ្រប់គ្រងវិបត្តិមួយ** ដោយបញ្ជាក់ពីតួនាទីរបស់អ្នកគ្រប់គ្រង និងបុគ្គលដែលទទួលខុសត្រូវផ្នែកសុវត្ថិភាព។
ii. ប្រមូលព័ត៌មានអំពីមនុស្សគួរឱ្យសង្ស័យនៅជុំវិញសាលា ខណៈសហការជាមួយគ្រួសារ និងអង្គការពាក់ព័ន្ធនៅក្នុងសហគមន៍។
iii. ចាត់វិធានការដែលអាចធ្វើទៅបាន និងមានប្រសិទ្ធភាពសមស្របតាមស្ថានភាពផ្សេងៗ។
iv. សហការជាមួយអង្គការ/ស្ថាប័នពាក់ព័ន្ធនៅក្នុងសហគមន៍ និងស្វែងរកកិច្ចសហប្រតិបត្តិការពីអាណាព្យាបាល និងសហគមន៍។
v. បង្កើត**សៀវភៅណែនាំគ្រប់គ្រងវិបត្តិ**ដែលសមស្របទៅនឹងស្ថានភាពសាលារៀន និងសហគមន៍។ នៅក្នុងដំណើរការនេះសូមបញ្ជាក់ពីអាទិភាពនៃការឆ្លើយតបក្នុងករណីមានឧបទ្ទវហេតុ/គ្រោះថ្នាក់។
vi. ធ្វើការបណ្ដុះបណ្ដាលដើម្បីអនុវត្តសៀវភៅណែនាំគ្រប់គ្រងវិបត្តិប្រកបដោយប្រសិទ្ធភាព។
vii. ផ្អែកលើបញ្ហាប្រឈមដែលទទួលបានតាមរយៈការបណ្ដុះបណ្ដាល សូមធ្វើការកែសម្រួលសៀវភៅណែនាំស្ដីពីការគ្រប់គ្រងវិបត្តិមានភាពប្រសើរឡើង។
viii. ផ្ដល់ការបណ្ដុះបណ្ដាលយ៉ាងសកម្មស្ដីពីការគ្រប់គ្រងវិបត្តិដល់បុគ្គលិកសាលាដើម្បីពង្រឹង និងរក្សាការយល់ដឹងអំពីការគ្រប់គ្រងវិបត្តិ។

ខ្លឹមសារដែលគួរដាក់បញ្ចូលក្នុងសៀវភៅណែនាំស្ដីពីការគ្រប់គ្រងវិបត្តិសម្រាប់ការទប់ទល់នឹង ជនសង្ស័យលបលួចចូលក្នុងសាលាមានតាមលំដាប់លំដោយដូចខាងក្រោម (**តារាងទី ១៤.៤**)។ វាមានសារៈសំខាន់ក្នុង<u>ការផ្ដល់អាទិភាពខ្ពស់បំផុតដល់ជីវិតរបស់មនុស្ស</u>ទៅក្នុងគ្រប់ខ្លឹមសារទាំងអស់។

**តារាងទី ១៤.៤៖ លំហូរនៃការគ្រប់គ្រងវិបត្តិក្នុងករណីមានជនសង្ស័យលបលួចចូល**

| ឈ្មោះសកម្មភាព | ការឆ្លើយតប |
|---|---|
| ការរកឃើញដំបូង និងការត្រួតពិនិត្យមនុស្សសង្ស័យ | • តាមគោលការណ៍ ត្រូវសួរបញ្ជាក់ពីគោលបំណងនៃការចូលមកមុនអនុញ្ញាតឱ្យបុគ្គលណាម្នាក់ចូលក្នុងបរិវេណសាលា<br>• នៅពេលមានមនុស្សសង្ស័យនៅក្នុងបរិវេណសាលាសូមនិយាយអ្វីមួយទៅកាន់បុគ្គលនោះ<br>• ស្នើឱ្យបុគ្គលដែលគ្មានហេតុផលត្រឹមត្រូវនោះចាកចេញ |
| ការបង្ការគ្រោះថ្នាក់ដល់មនុស្ស | • នៅពេលបុគ្គលិកសាលាបានដឹងអំពីគ្រោះថ្នាក់ ឬមានការសង្ស័យ សូមទាក់ទងទៅបុគ្គលិកសាលាដទៃទៀតក៏ដូចជានគរបាល និងអង្គការពាក់ព័ន្ធ<br>• ប្រសិនបើបុគ្គលនោះព្យាយាមប្រើអំពើហិង្សា សូមចាត់វិធានការការពារសមស្រប និងភ្លាមៗ និងជម្លៀស និងជួយសិស្ស |

| ឈ្មោះសកម្មភាព | ការឆ្លើយតប |
|---|---|
| | • ប្រសិនបើមាននរណាម្នាក់រងរបួស សូមផ្តល់ការសង្គ្រោះបឋមដល់បុគ្គលនោះ ហើយពិនិត្យពីសុវត្ថិភាពរបស់មនុស្សទាំងអស់ជាបន្ទាន់ |
| ការឆ្លើយតបសមស្រប ជាបន្តបន្ទាប់ | • បង្កើតអង្គការភ្លាមៗសម្រាប់ការឆ្លើយតបក្រោយឧបទ្ទវហេតុ<br>• ចាប់យកស្ថានភាពនៃឧបទ្ទវហេតុ និងចងក្រងព័ត៌មាន<br>• ទាក់ទងអាណាព្យាបាល<br>• ចាត់វិធានការដើម្បីបង្ការការកើតឡើងវិញ<br>• បង្កើតប្រព័ន្ធមួយសម្រាប់ផ្តល់ការថែទាំសុខភាពផ្លូវចិត្តក្រោយឧបទ្ទវហេតុ ដល់សិស្សសាលា បុគ្គលិកសាលា និងអាណាព្យាបាល |
| បញ្ហាទូទៅ | • ប្រមូលព័ត៌មាននៅកន្លែងតែមួយ (ឧទាហរណ៍ ពីនាយកសាលា) ហើយធ្វើរបាយការណ៍ឱ្យបានត្រឹមត្រូវ<br>• ពិនិត្យមើលម្តងមួយៗថា តើស្ថានភាពនោះត្រូវបានដោះស្រាយបានត្រឹមត្រូវ ឬនៅ ហើយធានាថា គ្មានអ្វីត្រូវមើលរំលងទេ |

**អត្ថបទដកស្រង់ ១៤.៣៖ កុមាររស់នៅក្នុងយុគសម័យឌីជីថល**[8]

*អង្គការមូលនិធិសង្គ្រោះកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (យូនីសេហ្វ) ថែងនៅក្នុងរបាយការណ៍របស់ខ្លួន «កុមារនៅក្នុងពិភពឌីជីថល (ឆ្នាំ២០១៧)»*[8] *ថា បច្ចេកវិទ្យាឌីជីថលបានផ្លាស់ប្តូរយ៉ាងច្រើនដល់ជីវិត និងឱកាសនៃជីវិតរបស់កុមារ។ របាយការណ៍បានចង្អុលបង្ហាញពីអត្ថប្រយោជន៍នៃបច្ចេកវិទ្យានេះដោយនិយាយថា ប្រសិនបើបច្ចេកវិទ្យាទទួលបានភាពស្មើគ្នាពីគ្រប់ទិសទីក្នុងពិភពលោកតាមវិធីត្រឹមត្រូវ នោះកុមារនឹងអាចភ្ជាប់ទៅនឹងឱកាសជីវិតនៅជុំវិញពិភពលោក និងទទួលបាននូវជំនាញ និងចំណេះដឹងពីប្រភពនៃការសិក្សាផ្សេងៗ ដោយយកឈ្នះលើគុណវិបត្តិដោយសារភាពក្រីក្រ ពូជសាសន៍ ជាតិពិន្ទ ភេទ និងស្ថានភាពភូមិសាស្ត្ររបស់ពួកគេ។*

*ទន្ទឹមនឹងនេះ បច្ចេកវិទ្យាឌីជីថលមានទាំងទិដ្ឋភាពអវិជ្ជមាន និងសុទិដ្ឋិនិយម។ ឧទាហរណ៍មួយគឺការបែងចែកឌីជីថលដល់ប្រទេសក្រីក្រ និងតំបន់ដាច់ស្រយាលនៅក្នុងប្រទេសទាំងនោះដែលមិនទាន់ទទួលព័ត៌មាន «សកល» ដោយសារតែហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណែតគ្មានភាពរីកចម្រើន។ លើសពីនេះទៅទៀត វាមានគ្រោះថ្នាក់ដល់ជីវិតរបស់កុមារលើអ៊ីនធឺណែតដូចជា ពង្រីកវិសាលភាពនៃគ្រោះថ្នាក់ដែលមានស្រាប់តួយ៉ាងដូចជា ការគំរាមកំហែងតាមអ៊ីនធឺណែត ការកើតឡើងនូវទម្រង់ថ្មីនៃការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទ និងគេហទំព័រដែលមានព័ត៌មានទាក់ទាញកុមារឱ្យធ្វើអត្តឃាតនិងប្រព្រឹត្តឧក្រិដ្ឋកម្ម។ វាធ្លាប់មានការខូចខាតធ្ងន់ធ្ងរ និងបែបមិនចេញមុខពីមនុស្សដែលនៅជុំវិញកុមារ។ អង្គការយូនីសេហ្វព្រមានថា ភាពមិនគ្រប់គ្រាន់ក្នុងការការពារសុវត្ថិភាពកំពុងធ្វើឱ្យកុមារប្រឈមនឹងហានិភ័យធំៗនៅលើអ៊ីនធឺណែត ជាពិសេសចំពោះតំបន់ដែលអ៊ីនធឺណែតបានរីករាលដាលនាពេលថ្មីៗនេះដូចជា តំបន់អាហ្វ្រិក និងតំបន់អាស៊ីអាគ្នេយ៍ជាដើម។*

*ជាការពិតណាស់ អាណាព្យាបាលមានការព្រួយបារម្ភអំពីបញ្ហាសុខភាពរបស់កូនចៅដូចជា ផលប៉ះពាល់ដល់សុខភាពភ្នែក ការញៀនអ៊ីនធឺណែត ការធ្លាក់ទឹកចិត្ត និងជំងឺធាត់។*

### អត្ថបទដកស្រង់ ១៤.៤៖ គ្រោះមហន្តរាយធម្មជាតិដែលតែងតែកើតឡើងនៅជុំវិញពិភពលោក

គ្រោះធម្មជាតិបានកើតឡើងជាញឹកញាប់ និងបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរនៅជុំវិញពិភពលោក។ គ្រាន់តែទឹកជំនន់មានរហូតដល់ទៅ ៤៧% នៃគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុទាំងអស់ (១៩៩៥-២០១៥) ដែលប៉ះពាល់ដល់ប្រជាជន ២,៣ពាន់លាននាក់ ដែលភាគច្រើន (៩៥%) រស់នៅក្នុងទ្វីបអាស៊ី។ វាមានការរាយការណ៍ថា ប្រហែល ៩០% នៃប្រជាជនដែលបាត់បង់ជីវិតគឺរស់នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប។[9] នៅក្នុងសហគមន៍អន្តរជាតិទសវត្សរ៍ឆ្នាំ១៩៩០ ត្រូវបានកំណត់ថាជា «ទសវត្សរ៍អន្តរជាតិសម្រាប់ការកាត់បន្ថយគ្រោះធម្មជាតិ» ហើយចាប់តាំងពីពេលនោះមក ការិយាល័យកាត់បន្ថយហានិភ័យមហន្តរាយរបស់អង្គការសហប្រជាជាតិ (UNDRR) បានផ្តួចផ្តើមលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងគោលបំណងកាត់បន្ថយការខូចខាតដោយសារគ្រោះធម្មជាតិ។

នេះគឺជាការចាំបាច់ក្នុងការផ្តល់ការអប់រំបង្ការទប់ស្កាត់គ្រោះមហន្តរាយនៅតាមសាលារៀន និងសហគមន៍ហើយពិចារណាថាតើសាលារៀនអាចធ្វើអ្វីខ្លះដើម្បីការពារអាយុជីវិតកុមារ និងអ្នករស់នៅសហគមន៍ក្នុងករណីមានគ្រោះធម្មជាតិ។

### អត្ថបទដកស្រង់ ១៤.៥៖ ការឆ្លើយតបនឹងរន្ទះ[10]

រន្ទះកើតឡើងដូចខាងក្រោម៖ ចរន្តអគ្គិសនីអាកាសកើតឡើងនៅពេលដែលខ្យល់ស្រាលឡើងកម្តៅដោយពន្លឺព្រះអាទិត្យនៅពេលថ្ងៃ ខណៈពេលដែលខ្យល់ត្រជាក់ផ្នែកខាងលើធ្លាក់ចុះមក។ ចរន្តអគ្គិសនីអាកាសនេះត្រូវបានបង្កើតឡើងនៅក្នុងពពក ហើយចរន្តអគ្គិសនីដែលពពកមិនអាចបង្កើតបានទៀតត្រូវបានផ្ទុះជារន្ទះ។ ផលប៉ះពាល់នានានៃរន្ទះលើរាងកាយមនុស្សគឺ **រន្ទះបាញ់** និង**រន្ទះខ្ទប់**។ រន្ទះបាញ់គឺជារន្ទះដែលវាយប្រហាររាងកាយមនុស្សដោយផ្ទាល់ពីពពក។ ក្នុងករណីនេះគេនិយាយថា មនុស្ស ៨០% បានបាត់បង់ជីវិត។ នៅទីវាលដូចជា តំបន់រាបស្មើ និងកំពូលភ្នំគឺជាកន្លែងមានគ្រោះថ្នាក់។ រន្ទះខ្ទប់ គឺជារន្ទះបាញ់ដែលលោតពីដើមឈើ ឬវត្ថុខ្ពស់ផ្សេងទៀតដែលរងរន្ទះបាញ់ផ្លាតមកត្រូវមនុស្សដែលនៅក្បែរដើមឈើ ឬឆក់អគ្គិសនីឆ្លងកាត់ដីពីដើមឈើដែលត្រូវរន្ទះបាញ់។

ការជម្លៀសទៅកាន់កន្លែងមានសុវត្ថិភាពមុនពេលរន្ទះបាញ់មានសារៈសំខាន់ណាស់។ នៅពេលអ្នកសម្គាល់ឃើញសញ្ញានៃរន្ទះបាញ់ដូចជា ពពកខ្មៅកំពុងរសាត់មកជិត ឬសំឡេងផ្គរលាន់ អ្នកត្រូវជ្រកនៅក្នុងផ្ទះ អគារ ឬរថយន្ត។ ការយកលោហធាតុចេញពីខ្លួន ឬពាក់អ៊ីសូឡង់ដូចជា ស្បែកជើងកៅស៊ូ**នឹងមិនការពារ**បុគ្គលពីរន្ទះបាញ់ឡើយ។

ប្រសិនបើគ្មានអគារណាអាចធ្វើជាជម្រកបានទេ អ្នកត្រូវជ្រកក្រោមវត្ថុខ្ពស់ដែលមានកម្ពស់យ៉ាងតិច ៥ម៉ែត្រ (ឧទាហរណ៍ បង្គោលភ្លើង បំពង់ផ្សែង ឬប៉មដែក)។ ពេលធ្វើដូច្នេះ សូមរក្សាចម្ងាយ ៤ម៉ែត្រ ឬច្រើនជាងនេះពីវត្ថុនោះខណៈស្ថិតនៅក្នុងទីតាំងមួយដែលអនុញ្ញាតឱ្យអ្នកក្រឡេកមើលឃើញផ្នែកកំពូលលើនៃវត្ថុនៅមុំ ៤៥ដឺក្រេ ឬច្រើនជាងនេះ។ ការនៅជិតពេកនឹងបង្កើនហានិភ័យនៃរន្ទះខ្ទប់។ ការឈ្ងោកមុខចុះ ឬការដេកលើដីក៏មានហានិភ័យច្រើនក្នុងការរងរន្ទះខ្ទប់ដែរ។ គួរ**ឱនចុះ និងរក្សាក្បាលឱ្យទាបតាមដែលអាចធ្វើទៅបាន** (រូបទី ១៤.២)។




**រូបទី ១៤.២៖** ការឆ្លើយតបពេលរន្ទះ[10]

## ៦ សុវត្ថិភាពសាលារៀន

ផ្នែកនេះពន្យល់ពីបញ្ញត្តិនៃសុវត្ថិភាពនៅសាលារៀន។[6] **សុវត្ថិភាពសាលារៀន**គួរត្រូវបានដោះស្រាយជាមួយសុខភាពសិក្សាតាមវិធីបញ្ច្រាបដើម្បីធានាសុខភាព និងសុវត្ថិភាពរបស់សិស្ស និងដើម្បីអភិវឌ្ឍចំណេះដឹងមូលដ្ឋានដែលអាចឱ្យពួកគេអភិវឌ្ឍសុខភាពផ្លូវចិត្ត និងរាងកាយ និងធានាសុវត្ថិភាពពេញមួយជីវិតរបស់ពួកគេ។ **សុវត្ថិភាពសាលារៀន**មានគោលបំណងអភិវឌ្ឍសមត្ថភាព/ជំនាញរបស់សិស្ស ដើម្បីប្រព្រឹត្តប្រកបដោយសុវត្ថិភាពដោយខ្លួនឯង និងរួមចំណែកដល់សុវត្ថិភាពអ្នកដទៃ និងសង្គមដោយឈរលើការគោរពចំពោះជីវិតផ្ទាល់ខ្លួនរបស់ពួកគេ និងអ្នកដទៃ ព្រមទាំងការបង្កើតបរិយាកាសដើម្បីធានាសុវត្ថិភាពរបស់សិស្ស។

សុវត្ថិភាពសាលារៀនមានបីវិស័យ៖ **សុវត្ថិភាពជីវិតប្រចាំថ្ងៃ សុវត្ថិភាពចរាចរណ៍ និងសុវត្ថិភាពគ្រោះមហន្តរាយ** (**ការបង្ការគ្រោះមហន្តរាយ**) (**តារាងទី ១៤.៥**)។

គ្រោះថ្នាក់ដែលអាចកើតមានឡើងនៅក្នុងជីវិតសិក្សារួមមាន ការធ្លាក់ដោយចៃដន្យពីជណ្ដើរ រានហាល ឬយ៉រដែលទាមទារឱ្យមានការយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការគ្រប់គ្រងសុវត្ថិភាពនៅក្នុងសាលារៀន។ លើសពីនេះទៅទៀត គ្រោះថ្នាក់ដែលបណ្ដាលមកពីការរចនាគ្រោងអគារ និងបរិក្ខារ/គ្រឿងសង្ហារិមចាស់ដែលមិនបានថែទាំត្រឹមត្រូវនៅតាមសាលារៀនមិនអាចមើលរំលងបានទេ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះមានការព្រួយបារម្ភអំពីព្រឹត្តិការណ៍សំខាន់ៗដែលទាញយកផលប្រយោជន៍ពីការផ្លាស់ប្ដូរបរិយាកាសជុំវិញសិស្សសាលាដូចជា ការរីករាលដាលនៃស្មាតហ្វូន និងបណ្ដាញសង្គម (SNS) និងសាលារៀនគោលដៅ (សូមមើលអត្ថបទដកស្រង់ ១៤.៣៖ កុមាររស់នៅក្នុងយុគសម័យឌីជីថល)។ ដោយសារព្រឹត្តិការណ៍សំខាន់ៗនៅជុំវិញសាលារៀនផ្លាស់ប្ដូរស្របនឹងពេលវេលា និងសង្គមផ្លាស់ប្ដូររបៀបរបបសុវត្ថិភាពសាលារៀនចាំបាច់ត្រូវពិនិត្យឡើងវិញដោយភាពបត់បែនដើម្បីឆ្លើយតបទៅនឹងការកើតឡើងនៃព្រឹត្តិការណ៍សំខាន់ថ្មីដែលមិនធ្លាប់បានគិតគូរនាពេលកន្លងមក។

សកម្មភាពដើម្បីសុវត្ថិភាពសាលាមានសកម្មភាពធំៗចំនួនបីគឺ**ការអប់រំសុវត្ថិភាព**ដែលមានគោលបំណងអភិវឌ្ឍសមត្ថភាពសិស្ស ឱ្យមានការប្រព្រឹត្តប្រកបដោយសុវត្ថិភាពដោយខ្លួនឯង និងរួមចំណែកដល់សុវត្ថិភាពអ្នកដទៃ និងសង្គមដោយការព្យាករណ៍ពីគ្រោះថ្នាក់ជាយថាហេតុផ្សេងៗបណ្ដាលមកពីការប្រព្រឹត្ត និងបរិយាកាសផ្ទាល់ខ្លួន។ **ការគ្រប់គ្រងសុវត្ថិភាព**ដែលមានគោលបំណងធ្វើឱ្យបរិយាកាសជុំវិញសិស្សមានសុវត្ថិភាព និង**សកម្មភាពរៀបចំ**ដែលជួយសម្រួលដល់សកម្មភាពទាំងពីរ។

**តារាងទី ១៤.៥៖ មាតិកាសំខាន់ៗនៃសុវត្ថិភាពសាលារៀន**

| វិស័យ | មាតិកា |
|---|---|
| សុវត្ថិភាពជីវិតប្រចាំថ្ងៃ | • របួសនិងគ្រោះថ្នាក់ពេលកំពុងសិក្សា ឬក្នុងជីវិតសិក្សា<br>• ឧបទ្ទវហេតុ និងគ្រោះថ្នាក់នៅក្នុងជីវិតគ្រួសារ<br>• ការបង្ការខូចខាតខាងព្រហ្មទណ្ឌ (ឧទាហរណ៍ ការចាប់ពង្រាត់ ការធ្វើទុក្ខដល់រាងកាយ ការលួច និងការរំលោភបំពានបណ្តាញ)<br>• កន្លែងគ្រោះថ្នាក់នៅតាមផ្លូវទៅសាលា ផ្លូវសុវត្ថិភាពក្នុងការធ្វើដំណើរទៅមកសាលារៀន<br>• សុវត្ថិភាពបរិស្ថានសាលារៀន (បរិក្ខារ/ការតំឡើងបរិក្ខារ) ការបង្កើតបរិស្ថានមានសុវត្ថិភាព |
| សុវត្ថិភាពចរាចរណ៍ | • គ្រោះថ្នាក់ សុវត្ថិភាព និងការបង្ការគ្រោះថ្នាក់នៅកន្លែងកើតហេតុផ្សេងៗ<br>• ការត្រួតពិនិត្យ/ថែទាំកង់ ការយល់ដឹងអំពីលក្ខណៈរបស់ម៉ូតូ ត្រីចក្រយាន និងរថយន្ត និងសុវត្ថិភាពពេលជិះ<br>• ការយល់ដឹងត្រឹមត្រូវ និងការគោរពច្បាប់ចរាចរណ៍<br>• ការបង្កើតសង្គមចរាចរណ៍មានសុវត្ថិភាពផ្អែកលើបច្ចេកវិទ្យាវិទ្យាសាស្ត្រថ្មី |
| សុវត្ថិភាពគ្រោះមហន្តរាយ<br>(ការបង្ការគ្រោះមហន្តរាយ) | • ការយល់ដឹងអំពីគ្រោះថ្នាក់នៃគ្រោះធម្មជាតិ (ឧទាហរណ៍ ការខូចខាតដោយសារខ្យល់ និងទឹកជំនន់ គ្រោះរាំងស្ងួត គ្រោះទុរភិក្ស ផ្គររន្ទះ រញ្ជួយដី ស៊ូណាមិ ភ្លើងឆេះព្រៃ និងភ្នំភ្លើង)<br>• ការយល់ដឹងអំពីគ្រោះថ្នាក់ក្នុងករណីមានអគ្គិភ័យ ឬគ្រោះមហន្តរាយ និងនីតិវិធីប្រតិបត្តិប្រកបដោយសុវត្ថិភាព<br>• ការប្រើប្រាស់ព័ត៌មានស្តីពីគ្រោះមហន្តរាយ និងការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយ<br>• ការថែទាំសុខភាពផ្លូវចិត្តក្នុងអំឡុង និងក្រោយពេលមានគ្រោះមហន្តរាយ |

ប្រភព៖ Created using references [1, 2, 11, 12]

## ៧ ការគ្រប់គ្រងវិបត្តិនៅតាមសាលារៀន

### ៧.១. បញ្ញត្តិនៃការគ្រប់គ្រងវិបត្តិនៅតាមសាលារៀន[6]

**ការគ្រប់គ្រងវិបត្តិនៅក្នុងសាលារៀន**ត្រូវតែឆ្លុះបញ្ចាំងពីការពិតរបស់សាលារៀន គ្រួសារ សហគមន៍ និងអង្គការពាក់ព័ន្ធ។ លើសពីនេះទៅទៀត គេត្រូវស្មានពីស្ថានភាពផ្សេងៗរួមទាំងពេលកំពុងសិក្សាទាំងក្នុង និងក្រៅសាលារៀន ពេលកំពុងធ្វើដំណើរ ពេលសម្រាក ពេលអាហារថ្ងៃត្រង់ ព្រឹត្តិការណ៍ សាលារៀន និងពេលនាយក នាយករងសាលា ឬបុគ្គលទទួលបន្ទុកផ្នែកសុវត្ថិភាពអវត្តមាន និងរៀបចំផែនការដោះស្រាយឧបទ្ទវហេតុ/គ្រោះថ្នាក់ (incident/accident) ផ្សេងៗ។ ហើយអ្វីដែលសំខាន់បំផុតគឺផ្តល់អាទិភាពខ្ពស់បំផុតដល់សន្តិសុខរបស់សិស្ស។ ឯកសារដែលចែងអំពីបញ្ហាទាំងនេះសម្រាប់គោលបំណងនៃការអនុវត្តរបស់ពួកគេឈ្មោះថា **ផែនការសុវត្ថិភាពសាលារៀន**។

ដើម្បីធ្វើការគ្រប់គ្រងវិបត្តិបានត្រឹមត្រូវ ចាំបាច់ត្រូវរៀបចំផែនការលម្អិតស្តីពីសុវត្ថិភាពសាលារៀនជាមុន។ ក្នុងការគិតគូរពីការធ្វើផែនការសុវត្ថិភាពសាលារៀនមានសកម្មភាពបីដែលទំនាក់ទំនងគ្នានោះគឺការអប់រំសុវត្ថិភាពការគ្រប់គ្រង

សុវត្ថិភាព និងការរៀបចំ។ ឯកសារដែលផ្តល់ជាពិសេសនូវប្រធានបទ និងនីតិវិធីចាំបាច់ដើម្បីឆ្លើយតបបានត្រឹមត្រូវទៅនឹងដំណើរការពីការកើតឡើងនៃគ្រោះថ្នាក់រហូតដល់លេចចេញនូវវិបត្តិ និងការស្តារសុវត្ថិភាពឡើងវិញហៅថា **សៀវភៅស្តីពីការគ្រប់គ្រងវិបត្តិ**។ ដោយផ្អែកលើប្រធានបទទាំងនេះ សាលារៀនត្រូវបង្កើតសៀវភៅណែនាំគ្រប់គ្រងវិបត្តិផ្ទាល់ខ្លួន និងចែករំលែកចំណេះដឹងដល់បុគ្គលិកសាលាទាំងអស់ដើម្បីឱ្យពួកគេអាចឆ្លើយតបបានត្រឹមត្រូវជារៀងរាល់ថ្ងៃក៏ដូចជាពេលមានអាសន្ន។ លើសពីនេះទៅទៀត គេចាំបាច់ត្រូវធ្វើការផ្ទៀងផ្ទាត់ និងកែលម្អជាបន្តបន្ទាប់។

## ៧.២. ការអនុវត្តជាក់ស្តែងនៃការគ្រប់គ្រងវិបត្តិនៅតាមសាលារៀន[10]

ការគ្រប់គ្រងវិបត្តិនៅក្នុងសាលារៀនត្រូវបានបែងចែកទៅជាការបង្ការឧបទ្ទវហេតុ/គ្រោះថ្នាក់តាមរយៈការរកឃើញគ្រោះថ្នាក់ជាមុន (ការបង្ការហានិភ័យ) ការធានាសុវត្ថិភាពរបស់កុមារ និងបុគ្គលិកសាលា (ការគ្រប់គ្រងហានិភ័យ) និងការពារការរីករាលដាលនៃការខូចខាតតាមរយៈការឆ្លើយតបភ្លាមៗនិងត្រឹមត្រូវចំពោះឧបទ្ទវហេតុ/គ្រោះថ្នាក់ក៏ដូចជាវិធានការជាបន្តបន្ទាប់ (ការគ្រប់គ្រងវិបត្តិ)។ ការគ្រប់គ្រងវិបត្តិនៅតាមសាលារៀនត្រូវបានចាត់ថ្នាក់ជាបួនដំណាក់កាលដូចខាងក្រោម (**តារាងទី ១៤.៦**)។ ខ្លឹមសារ និងលំហូរនៃដំណាក់កាលទាំងនេះត្រូវបានពន្យល់ជាពិសេសដូចខាងក្រោម៖

**តារាងទី ១៤.៦៖ មាតិកាសំខាន់ៗនៃសុវត្ថិភាពសាលារៀន**

| ដំណាក់កាល | ប្រធានបទនៃការគ្រប់គ្រងវិបត្តិ | សកម្មភាពជាក់លាក់ |
|---|---|---|
| ១. ការបង្ការ | ការបង្ការការកើតឡើងនៃឧបទ្ទវហេតុ/គ្រោះថ្នាក់ | ការត្រួតពិនិត្យសុវត្ថិភាព ការអភិវឌ្ឍ**សមត្ថភាពរបស់កុមារក្នុងការទស្សន៍ទាយ និងចៀសវាងគ្រោះថ្នាក់** |
| ២. ការត្រៀមខ្លួន | ត្រៀមខ្លួនចំពោះការកើតឡើងនៃឧបទ្ទវហេតុ/គ្រោះថ្នាក់ | ការបង្កើតប្រព័ន្ធគ្រប់គ្រងវិបត្តិ កិច្ចសហការជាមួយអង្គការ/ស្ថាប័នពាក់ព័ន្ធ ការគាំទ្រពីអ្នកអាណាព្យាបាល និងប្រជាពលរដ្ឋក្នុងសហគមន៍ ការបង្កើតសៀវភៅណែនាំស្តីពីគ្រប់គ្រងវិបត្តិ ការបណ្តុះបណ្តាល |
| ៣. ការឆ្លើយតប | ឆ្លើយតបភ្លាមៗទៅនឹងឧបទ្ទវហេតុ/គ្រោះថ្នាក់ | សន្តិសុខរបស់កុមារ និងបុគ្គលិកសាលា ការក្តាប់ស្ថានភាព ការថែទាំសុខភាពបន្ទាន់ ការបង្ការ/កាត់បន្ថយការរីករាលដាលនៃការខូចខាត |
| ៤. ការស្តារឡើងវិញ | ការឆ្លើយតបបន្ទាប់ពីឧបទ្ទវហេតុ/គ្រោះថ្នាក់ និងការស្តារឡើងវិញ | ការទំនាក់ទំនង/ការពន្យល់ដល់អ្នកអាណាព្យាបាល និងមនុស្សដែលពាក់ព័ន្ធ ការរៀបចំដំណើរការអប់រំឡើងវិញ វិធានការបង្ការការកើតឡើងវិញនៃឧបទ្ទវហេតុ/គ្រោះថ្នាក់ ការថែទាំសុខភាពផ្លូវចិត្ត ការពិនិត្យឡើងវិញនៃប្រព័ន្ធគ្រប់គ្រងវិបត្តិ |

ប្រភព៖ Created using rerence[10]

### ៧.២.១. ការបង្ការការកើតឡើងនៃឧបទ្ទវហេតុ/គ្រោះថ្នាក់ [ការបង្ការ]

ការត្រួតពិនិត្យសម្ភារៈបរិក្ខារ/គ្រឿងសង្ហារឹម និងឧបករណ៍នៅក្នុងសាលារៀន ព្រមទាំងសុវត្ថិភាពតាមផ្លូវទៅសាលាគឺជាទិដ្ឋភាពសំខាន់មួយនៃការគ្រប់គ្រងវិបត្តិដើម្បីការពារសិស្សកុំឱ្យពាក់ព័ន្ធក្នុងឧបទ្ទវហេតុ/គ្រោះថ្នាក់ផ្សេងៗ។ កិច្ចខិតខំប្រឹងប្រែងដើម្បី «ស្រង់ចេញ» «វិភាគ» និង «គ្រប់គ្រង» កន្លែងគ្រោះថ្នាក់នៅក្នុងបរិយាកាសនៃជីវិតអ្នកសិក្សាដូចជាការធ្វើដំណើរទៅ និងមកពីសាលារៀនចាំបាច់ត្រូវធ្វើឱ្យមានលក្ខណៈជាប្រព័ន្ធដោយផ្អែក**លើវដ្តនៃផែនការ-អនុវត្ត-ត្រួតពិនិត្យ-សកម្មភាព (PDCA)**។

## ក. ការស្រង់យកចំណុចគ្រោះថ្នាក់

ប្រើព័ត៌មានបីប្រភេទខាងក្រោមនេះសម្រាប់ជាសំអាងដើម្បីស្រង់យកកន្លែងប្រឈមនឹងគ្រោះថ្នាក់កើតឡើង។

i. ព័ត៌មានដែលផ្តល់ដោយបុគ្គលិកសាលា សិស្ស អ្នកអាណាព្យាបាល និងសហគមន៍

ប្រមូលព័ត៌មានពីអ្នកពាក់ព័ន្ធទាំងអស់ដូចជា បុគ្គលិកសាលា សិស្ស អ្នកអាណាព្យាបាល និងសហគមន៍អំពីទីកន្លែងដែលពួកគេបានរងរបួសនៅក្នុងសាលារៀន ឬកន្លែងដែលពួកគេជួបគ្រោះថ្នាក់នៅពេលធ្វើដំណើរទៅ ឬមកពីសាលារៀន ហើយដៅសម្គាល់ទីតាំងទាំងនោះនៅលើផែនទីក្នុងមូលដ្ឋាន។ កំណត់ទីកន្លែងដែលសិស្សភាគច្រើនបានរងរបួស និងកន្លែងប្រឈមដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ធំ ហើយបង្រួមកន្លែងដែលត្រូវផ្តល់អាទិភាពក្នុងការចាត់វិធានការ។

ii. ព័ត៌មានអំពីការកើតឡើងនៃគ្រោះថ្នាក់កន្លងមក

ឧទាហរណ៍ កន្លែងដែលមានការចាប់ពង្រត់ ឬឧបទ្ទវហេតុដែលគួរឱ្យសង្ស័យធ្លាប់កើតឡើងកាលពីអតីតកាល កន្លែងដែលសិស្សបានរងរបួស និងកន្លែងដែលបង្ហៀរទឹកមានទឹកឡើងខ្ពស់ដែលត្រូវបានកត់ត្រាទុកជាភស្តុតាងច្បាស់លាស់ និងដាក់បញ្ចូលនៅក្នុងកន្លែងគ្រោះថ្នាក់ជាអាទិភាព។

iii. ព័ត៌មានអំពីលក្ខខណ្ឌនៃការកើតឡើងនៃគ្រោះថ្នាក់

ការកើតឡើងនៃគ្រោះថ្នាក់ទាក់ទងនឹងប្រភេទលក្ខខណ្ឌបរិស្ថាន។ ប្រើផែនទីគោលគ្រោះថ្នាក់ និងបញ្ជីត្រួតពិនិត្យសម្រាប់ជាឯកសារយោងដើម្បីស្វែងរកលក្ខខណ្ឌបរិស្ថានដែលអាចជាប់ទាក់ទងនឹងគ្រោះថ្នាក់នៅសាលារៀន ឬក្នុងបរិយាកាសធ្វើដំណើរ ហើយពិនិត្យមើលស្ថានភាពនោះជាប្រចាំ/មិនទៀងទាត់/ប្រចាំថ្ងៃ។ ការធ្វើត្រួតពិនិត្យប្រចាំថ្ងៃចំពោះវត្ថុសង្ស័យក៏ជាការសំខាន់ដែរ។

ជាព័ត៌មានសម្រាប់អ្នក៖ <u>ផែនទីគ្រោះថ្នាក់ គឺជាផែនទីដែលចង្អុលបង្ហាញទីកន្លែងគ្រោះថ្នាក់ និងកន្លែងជម្លៀសក្នុងករណីមានគ្រោះមហន្តរាយណាមួយ ហើយផែនទីនេះខុសគ្នាទៅតាមប្រភេទគ្រោះមហន្តរាយ</u>។

## ខ. ការវិភាគកន្លែងគ្រោះថ្នាក់

វិភាគកន្លែងគ្រោះថ្នាក់ដែលបានជ្រើសរើស ដើម្បីទទួលបានរូបភាពជាក់ស្តែងនៃគ្រោះថ្នាក់ដែលអាចកើតមាន និងកំណត់លក្ខខណ្ឌបរិស្ថានទាំងឡាយណាដែលអាចបង្កបញ្ហា។

i. ការវិភាគគោលបំណងតាមរយៈភ្នែកមនុស្សជាច្រើន

ធ្វើការត្រួតពិនិត្យរួមគ្នាជាមួយភាគីពាក់ព័ន្ធ ហើយ<u>សង្កេត និងវិភាគកន្លែងគ្រោះថ្នាក់តាមរយៈភ្នែកមនុស្សជាច្រើន</u>។ ជាការល្អ ចូរស្វែងរកកិច្ចសហប្រតិបត្តិការពីអ្នកជំនាញដើម្បីធ្វើការវិភាគលម្អិតបន្ថែមទៀត។ ទាក់ទងទៅនឹងស្ថានភាពនៃការខូចខាតនៅពេលគ្រោះថ្នាក់បានកើតឡើង និងទីកន្លែងនៃការកើតឡើងសូមកំណត់លក្ខខណ្ឌបរិស្ថានដែលជាកត្តានៃការកើតឡើង។

ii. ការវិភាគអំពីឥរិយាបថរបស់សិស្ស

<u>ការកើតឡើងនៃគ្រោះថ្នាក់ជាច្រើនជាប់ទាក់ទងទៅនឹងលក្ខណៈឥរិយាបថរបស់សិស្ស</u>។ សង្កេតមើលពីការប្រព្រឹត្តរបស់សិស្សនៅកន្លែងគ្រោះថ្នាក់ក្នុងសាលារៀន និងនៅតាមផ្លូវទៅសាលារៀន និងទទួលបានរូបភាពជាក់ស្តែងនៃគ្រោះថ្នាក់ដែលអាចកើតមាន។ បន្ទាប់ពីនេះសូមស្វែងរកលក្ខខណ្ឌបរិស្ថាន និងបញ្ហាប្រឈមនៅក្នុងការណែនាំដែលគួរកែលម្អ។

iii. ការស្ទង់មើលរបស់សិស្ស

<u>ការវិភាគរបស់សិស្សអំពីកន្លែងគ្រោះថ្នាក់គឺមានប្រយោជន៍ ពីព្រោះនាំឱ្យគេកំណត់បានពីបញ្ហាចេញពីការមើលឃើញរបស់សិស្សក៏ដូចជាការអប់រំសុវត្ថិភាពរបស់សិស្សខ្លួនឯង</u>។ ការប្រមូលព័ត៌មានពីសិស្សអំពីបទពិសោធន៍គ្រោះថ្នាក់របស់ពួកគេ និងបង្កើត**ផែនទីសុវត្ថិភាពក្នុងមូលដ្ឋាន** បន្ទាប់មកផ្លាស់ប្តូរយោបល់ជាមួយអ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ ក៏មានប្រសិទ្ធភាពផងដែរ។

### គ. ការគ្រប់គ្រងកន្លែងគ្រោះថ្នាក់ និងរចនាសម្ព័ន្ធការងារ

តាមរយៈការស្រង់ចេញ និងវិភាគរកចំណុចគ្រោះថ្នាក់ សូមគិតគូរពីគម្រោងកែលម្អជាក់ស្ដែងដើម្បីចាត់វិធានការ។ សាលារៀន គ្រួសារ និងសហគមន៍ចាំបាច់ត្រូវរួមគ្នាជាប្រព័ន្ធមួយ ដើម្បីលើកកម្ពស់ការពិភាក្សាអំពីសកម្មភាព ព្រមទាំងការត្រួតពិនិត្យជាប្រចាំ។

## ៧.២.២. ត្រៀមរៀបចំសម្រាប់ការកើតឡើងនៃឧបទ្ទវហេតុ/គ្រោះថ្នាក់ [ការត្រៀមរៀបចំ]

### ក. ការហ្វឹកហាត់ការជម្លៀស

**ការហ្វឹកហាត់ការជម្លៀស**ត្រូវបានធ្វើឡើងដើម្បីបង្ហាញពីតួនាទីរបស់បុគ្គលិកសាលាដែលមានចែងនៅក្នុងសៀវភៅណែនាំស្ដីពីការគ្រប់គ្រងវិបត្តិនិងបណ្ដុះនូវអាកប្បកិរិយានិងសមត្ថភាពជាក់ស្ដែងរបស់សិស្សក្នុងការជម្លៀសចេញដោយសុវត្ថិភាពក្នុងករណីមានគ្រោះអាសន្ន។

**សកម្មភាពជម្លៀស**គឺជា «សកម្មភាពការពារជីវិត» ពីគ្រោះថ្នាក់ដែលអាចកើតមានឡើងនៅប៉ុន្មានវិនាទី នាទី និងប៉ុន្មានម៉ោងបន្ទាប់។ បញ្ហាខាងក្រោមនេះត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់មុនពេលការហ្វឹកហាត់ការជម្លៀសតាមដែលអាចធ្វើទៅបានដោយពិចារណាថា តើប្រភេទគ្រោះថ្នាក់អ្វីខ្លះដែលអាចគំរាមកំហែងដល់អាយុជីវិតនិងសុខភាពរាងកាយរបស់សិស្សដោយប្រកាន់យកទស្សនៈនៃការពារពួកគេ។

i. តើប្រភេទគ្រោះថ្នាក់អ្វីខ្លះដែលអាចបង្កឡើង? ការជម្លៀសចេញពីអ្វីខ្លះ?
ii. តើប្រភេទនៃការជម្លៀសអ្វីខ្លះដែលគួរត្រូវបានយកមកអនុវត្តចំពោះគ្រោះថ្នាក់នីមួយៗ?
iii. តើពេលណាដែលសកម្មភាពជម្លៀសគួរតែត្រូវបានផ្ដួចផ្ដើម?

### ខ. ផែនការជម្លៀសក្នុងករណីមានគ្រោះថ្នាក់

សកម្មភាពជម្លៀសក្នុងករណីគ្រោះថ្នាក់ប្រែប្រួលទៅតាមប្រភេទ និងទំហំនៃគ្រោះថ្នាក់ ព្រមទាំងលក្ខណៈ និងស្ថានភាពនីមួយៗ។ ឧបមាថា សកម្មភាពជម្លៀសគឺជា «សកម្មភាពធានានូវសន្តិសុខដើម្បីគេចផុតពីគ្រោះថ្នាក់» សកម្មភាពទាំងនោះចែកជា «រង់ចាំ (នៅកន្លែងកើតហេតុ)» «ផ្លាស់ទីទៅខាងលើ (ឧទាហរណ៍ ផ្លាស់ទៅកន្លែងមានសុវត្ថិភាពនៅជាន់ទី ២ ឬខ្ពស់ជាងនេះ)» និង «ផ្លាស់ទីចេញ (ឧទាហរណ៍ ផ្លាស់ទៅកន្លែងជម្លៀស បណ្ដោះអាសន្ន ឬរយៈពេលយូរ)» ក្នុងករណីមានទីធ្លា។ ដូច្នេះសំខាន់ត្រូវគិតគូរពីករណីទាំងនេះ ហើយពិចារណាជាមុនថាតើសកម្មភាពអ្វីដែលត្រូវធ្វើនៅពេលមានគ្រោះថ្នាក់។ លើសពីនេះទៅទៀត សកម្មភាពជម្លៀសដែលសន្មតថាមាន**គ្រោះមហន្តរាយបន្ទាប់បន្សំ** (ឧទាហរណ៍ គ្រោះមហន្តរាយជាបន្តបន្ទាប់ដែលបង្កឡើងដោយគ្រោះមហន្តរាយមុន) ក៏ត្រូវពិចារណាទុកជាមុនផងដែរ។

ក្នុងករណីគ្រោះថ្នាក់សាលារៀនត្រូវការពារអាយុជីវិតនិងសុខភាពរាងកាយរបស់សិស្សដោយបង្កើតទីស្នាក់ការគ្រោះមហន្តរាយ ដើម្បីជួយបុគ្គលិកសាលាទាំងអស់បំពេញតួនាទីរបស់ពួកគេដូចជា ការប្រមូលព័ត៌មាន ការណែនាំអំពីការជម្លៀស និងសកម្មភាពជួយសង្គ្រោះ។ ដើម្បីធានាបាននូវការបំពេញតួនាទីទាំងនេះចាំបាច់<u>ត្រូវបង្កើតសៀវភៅស្ដីពីការគ្រប់គ្រងវិបត្តិជាមុនសិន និងដើម្បីចែករំលែកការយល់ដឹងរួមដល់បុគ្គលិកសាលាទាំងអស់</u>។

ចាំបាច់ត្រូវរៀបចំផែនការជម្លៀស និងបញ្ចូលផែនការនេះទៅក្នុងសៀវភៅស្ដីពីការគ្រប់គ្រងវិបត្តិដោយកំណត់ទីកន្លែងជម្លៀស និងផ្លូវជម្លៀសជាលក្ខណៈបុគ្គល និងជាពិសេសដោយផ្អែកលើលក្ខណៈទីតាំង និងភូមិសាស្ត្រនៃបរិស្ថានសាលារៀន និងតំបន់ជុំវិញព្រមទាំងផែនទីគ្រោះថ្នាក់ដែលបង្កើតឡើងដោយអាជ្ញាធរ និងអង្គការមូលដ្ឋាន។

## ៧.២.៣. ឆ្លើយតបភ្លាមៗចំពោះឧបទ្ទវហេតុ/គ្រោះថ្នាក់ [ការឆ្លើយតប]

ក្នុងករណីមានគ្រោះថ្នាក់នៅសាលារៀន វាចាំបាច់ចំពោះគណៈកម្មការសាលាដែលបានបង្កើតសាលារៀន (នាយកសាលា) ត្រូវចាត់វិធានការភ្លាមៗ និងត្រឹមត្រូវដោយផ្តល់អាទិភាពខ្ពស់បំផុតដល់ជីវិត និងសុខភាពរបស់សិស្ស (**រូបទី ១៤.៣**)។ ដើម្បីសម្រេចកិច្ចការនេះបាន សំខាន់សាលារៀនត្រូវមានប្រព័ន្ធបត់បែនដែលជាអង្គការមួយ ហើយចំពោះបុគ្គលិកសាលាទាំងអស់ត្រូវតែស្វែងយល់ និងចេះពីនីតិវិធីក្នុងការព្យាបាលអ្នកជំងឺ (របួស) ឱ្យបានឆាប់រហ័ស និងត្រឹមត្រូវដោយមិនស្ទាក់ស្ទើរ (សូមមើលជំពូកទី ១៥)។

នៅពេលឃើញមានសិស្សឈឺ (របួស) វាសំខាន់ចំពោះអ្នកមកដល់កន្លែងកើតហេតុមុនគេត្រូវពិនិត្យមើលស្ថានភាពរបួសរបស់សិស្ស ហើយស្នើបុគ្គលិក និងសិស្សដែលនៅក្បែរនោះឱ្យជួយ ខណៈពេលកំពុងការពារកុំឱ្យអាការៈកាន់តែធ្ងន់ធ្ងរដោយផ្តល់ការសង្គ្រោះបឋមដូចជា ឃាត់ឈាមភ្លាមៗ និងផ្តល់ការធ្វើចលនាបេះដូងឱ្យដើរឡើងវិញ (CPR) ទៅតាមស្ថានភាពរបួសរបស់សិស្ស។ ក្នុងករណីមានគ្រោះថ្នាក់ តម្រូវឱ្យអនុវត្តការងារជាច្រើនក្នុងពេលដំណាលគ្នារួមទាំងការទាក់ទងអ្នកអាណាព្យាបាលសិស្សដែលរងរបួស និងការមើលថែទាំសិស្សផ្សេងទៀតបន្ថែមពីលើការសង្គ្រោះបឋម។ បុគ្គលិកសាលាទាំងអស់ត្រូវមានការយល់ដឹងរួមអំពីអ្វីដែលគួរធ្វើឱ្យបានឆាប់រហ័សដើម្បីឱ្យពួកគេអាចឆ្លើយតបបានជាប្រព័ន្ធ។ ក្នុងការទាក់ទងអ្នកអាណាព្យាបាលរបស់សិស្ស ដែលរងរបួសសូមទាក់ទងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីការរៀបចំព័ត៌មានអប្បបរមាដែលត្រូវការអំពីស្ថានភាពទូទៅនៃគ្រោះថ្នាក់ និងកម្រិតនៃការរងរបួស (ឧទាហរណ៍ របួសតូចតាច មធ្យម និងធ្ងន់ធ្ងរ)។

ក្នុងករណីដែលត្រូវការការឆ្លើយតបបន្ទាន់ដូចជា ជីវិតរបស់សិស្សដែលរងរបួសកំពុងរងការគំរាមកំហែង ត្រូវចាត់វិធានការភ្លាមៗដោយផ្តល់អាទិភាពខ្ពស់លើការព្យាបាលសង្គ្រោះជីវិតជាងការរាយការណ៍ទៅអ្នកគ្រប់គ្រង។ បុគ្គលិកសាលាត្រូវអនុវត្តវិធីសាស្ត្រដើម្បីកាត់បន្ថយការថប់បារម្ភរបស់សិស្សដទៃទៀតដោយគ្មានការរំជួលចិត្តពីស្ថានភាពគ្រោះថ្នាក់ ឬស្ថានភាពរបស់សិស្សដែលរងរបួស។ ព្យាយាមទុកកំណត់ហេតុតាមតម្រូវការទាក់ទងនឹងការកើតឡើងនៃគ្រោះថ្នាក់ វិធានការដែលបានអនុវត្តបន្ទាប់ពីហេតុការណ៍ និងលទ្ធផលនៃវិធានការទាំងនោះ អំឡុងពេលផ្តល់អាទិភាពដល់ការសង្គ្រោះបឋម នឹងរៀបចំខ្លឹមសារនៃរបាយការណ៍អំពីស្ថានការណ៍បានកើតឡើងជាបណ្តោះអាសន្ន។




**រូបទី ១៤.៣៖** ឧទាហរណ៍នៃការឆ្លើយតបក្នុងករណីមានឧបទ្ទវហេតុ/គ្រោះថ្នាក់នៅក្នុងសាលារៀន (សង្គ្រោះបឋម/ប្រព័ន្ធទំនាក់ទំនងសង្គ្រោះបន្ទាន់)

### ៧.២.៤. ការឆ្លើយតបជាបន្តបន្ទាប់ចំពោះឧបទ្ទវហេតុ/គ្រោះថ្នាក់ និងការស្តារឡើងវិញ [ការស្តារឡើងវិញ]

ទាក់ទងនឹងគ្រោះថ្នាក់នៅសាលារៀន គណៈកម្មការដែលបង្កើតសាលារៀន (នាយកសាលា) ចាំបាច់ត្រូវផ្តល់ដំបូន្មាន និងអនុវត្តវិធានការបង្ការការកើតឡើងវិញដោយការស៊ើបអង្កេតរកមូលហេតុ និងផ្ទៀងផ្ទាត់វិធានការសុវត្ថិភាពពីមុន និងផ្តល់ការពន្យល់គ្រប់គ្រាន់រួចបន្តការគាំទ្រដល់អ្នកអាណាព្យាបាលសិស្សដែលរងរបួស។

ជាពិសេស រៀបចំព័ត៌មានលម្អិតអំពីការកើតឡើងនៃគ្រោះថ្នាក់នៅពេលការឆ្លើយតបដែលត្រូវការភ្លាមៗបន្ទាប់ពីគ្រោះថ្នាក់។ ប្រមូលព័ត៌មានពិស្តារអំពីមូលហេតុបណ្តាលឱ្យមានគ្រោះថ្នាក់ ធ្វើការស្រាវជ្រាវ/ផ្ទៀងផ្ទាត់សំដៅបង្ការគ្រោះថ្នាក់នាពេលអនាគត និងប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវដើម្បីបង្ការការកើតឡើងវិញ។

## ៧.៣. បទពិសោធន៍នៃឧបទ្ទវហេតុ/គ្រោះថ្នាក់ និងការថែទាំសុខភាពផ្លូវចិត្ត[2,10]

ការជួបឧបទ្ទវហេតុ/គ្រោះថ្នាក់អាចធ្វើឱ្យសិស្សបាក់ស្បាតដោយសារការភ័យខ្លាច ឬការបាត់បង់បទពិសោធន៍។ ពួកគេអាចលេចចេញរោគសញ្ញាដូចជា ការនឹកឃើញព្រឹត្តិការណ៍ម្តងហើយម្តងទៀត ឬការបង្កើតព្រឹត្តិការណ៍ឡើងវិញនៅពេលលេងក៏ដូចជា អារម្មណ៍មិននឹងនរ និងបញ្ហាដំណេកដែលបណ្តាលឱ្យមានបញ្ហាធ្ងន់ធ្ងរនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ប្រតិកម្មទាំងនេះអាចកើតឡើងចំពោះមនុស្សគ្រប់រូប ហើយករណីភាគច្រើនថយចុះវិញតាមពេលវេលា។ ប៉ុន្តែប្រសិនបើស្ថានភាពនេះនៅតែបន្តកើតមានពីរបីថ្ងៃទៅមួយខែបន្ទាប់ពីជួបឧបទ្ទវហេតុ/គ្រោះថ្នាក់ហៅថា **ជំងឺស្ត្រេសស្រួចស្រាវ (Acute Stress Disorder (ASD))** ហើយប្រសិនបើវានៅតែបន្តកើតមានរយៈពេលមួយខែ ឬយូរជាងនេះហៅថា **ជំងឺបាក់ស្បាត (Post-Traumatic Stress Disorder (PTSD))**។ ដូច្នេះសំខាន់ត្រូវចាប់ផ្តើមផ្តល់ការគាំទ្រដល់សិស្ស និងអ្នកអាណាព្យាបាលរបស់ពួកគេភ្លាមៗបន្ទាប់ពីឧបទ្ទវហេតុ/គ្រោះថ្នាក់សម្រាប់ការបង្ការ និងការរកឃើញជំងឺបាក់ស្បាត PTSD នៅដំណាក់កាលដំបូង។ គួរកត់សម្គាល់ថាមានករណីដែលសិស្សអភិវឌ្ឍ ASD ភ្លាមៗបន្ទាប់ពីជួបគ្រោះថ្នាក់ ហើយបន្ទាប់មកក្លាយទៅជាជំងឺបាក់ស្បាត PTSD ពុំតែប៉ុណ្ណោះក៏ដូចជាករណីដែលរោគសញ្ញាមិនត្រូវបានកត់សម្គាល់នៅដំណាក់កាលដំបូង និងករណីដែលមានរោគសញ្ញាត្រូវបានថយចុះម្តង ប៉ុន្តែជំងឺលេចឡើងពីរបីខែក្រោយមកទៀត។ ដូច្នេះសំខាន់ត្រូវផ្តល់ការថែទាំសុខភាពផ្លូវចិត្តឱ្យបានយូរតាមដែលអាចធ្វើទៅបាន (សូមមើលជំពូកទី ១២)។

លើសពីនេះទៅទៀត អ្នកអាណាព្យាបាលសិស្សដែលរងរបួស និងបុគ្គលិកសាលាអាចប្រហែលទុកខ្លួនឯងចោល ឬមិនដឹងថាខ្លួនមានជំងឺផ្នែករាងកាយ និងផ្លូវចិត្តឡើយ។ ដូច្នេះហើយពួកគេអាចត្រូវការថែទាំសុខភាពផ្លូវចិត្តសម្រាប់ខ្លួនឯង។ ចំពោះសិស្សដែលរងរបួស វាសំខាន់ដែលអ្នកអាណាព្យាបាល និងបុគ្គលិកសាលានៅជុំវិញពួកគេត្រូវមានស្ថិរភាពផ្លូវចិត្ត។ ដូច្នេះហើយបានជាមនុស្សទាំងអស់ដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់គប្បីត្រូវស្វែងយល់ថា ពួកគេត្រូវការការថែទាំសុខភាពផ្លូវចិត្តដូចជា ការកត់សម្គាល់ពីបញ្ហាផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេឱ្យបានឆាប់តាមដែលអាចធ្វើទៅបានដើម្បីសម្រាក ឬមានការពិគ្រោះយោបល់ជាមុន។

### ៧.៣.១. ការថែទាំសុខភាពផ្លូវចិត្តភ្លាមៗបន្ទាប់ពីមានវិបត្តិកើតឡើង

ដូចរបួសរាងកាយដែរ របួសផ្លូវចិត្តគឺត្រូវការសង្គ្រោះបឋម។ **ការសង្គ្រោះផ្លូវចិត្តបឋម (Psychological First Aid (PFA))** ត្រូវបានទទួលយកទូទាំងពិភពលោកថាជាវិធីសាស្ត្រមូលដ្ឋាននៃការថែទាំសុខភាពផ្លូវចិត្តដែលផ្តល់ភ្លាមៗបន្ទាប់ពីមានវិបត្តិកើតឡើង។ PFA ផ្តល់នូវខ្លឹមសារជាក់លាក់ និងនីតិវិធីរួមនៃការថែទាំសុខភាពផ្លូវចិត្តដែលត្រូវបានផ្តល់ជូនភ្លាមៗបន្ទាប់ពីមានវិបត្តិកើតឡើង។

ក្របខណ្ឌនៃការបោះពុម្ពផ្សាយ**ឯកសារសង្គ្រោះផ្លូវចិត្តបឋមសម្រាប់សាលារៀន (Psychological First Aid School Edition (PFA-S))**[13] មានសកម្មភាពសំខាន់ៗចំនួន ៨ (**តារាងទី ១៤.៧**)។ PFA-S ចាត់ទុកវាជារឿងធម្មតាដែលសិស្ស និងបុគ្គលិកសាលាបង្ហាញការឆ្លើយតបផ្សេងៗគ្នា (ឧទាហរណ៍ បញ្ហារាងកាយ ការយល់ដឹង ឥរិយាបថ

និងបញ្ហាស្មារតី) បន្ទាប់ពីស្ថានភាពអាសន្ន។ ការថែទាំដែលផ្តល់ដោយអ្នកជំនាញផ្នែកការជួយសង្គ្រោះពីគ្រោះមហន្តរាយ និងសុខភាពផ្លូវចិត្តអាចជួយសិស្ស និងបុគ្គលិកសាលាឱ្យជាសះស្បើយពីការឆ្លើយតបទាន់ពេលវេលា និងការនាំយកការថែទាំបែបនេះទៅជាជំនួយដែលត្រូវនឹងតម្រូវការរបស់មនុស្សម្នាក់ៗនឹងអាចការពារពេគសញ្ញាមិនឱ្យធ្ងន់ធ្ងរ ឬបន្តកើតមានក្នុងរយៈពេលយូរ។

**តារាងទី ១៤.៧៖ ក្របខណ្ឌនៃការបោះពុម្ពផ្សាយឯកសារសង្គ្រោះផ្លូវចិត្តបឋមសម្រាប់សាលារៀន**

| សកម្មភាព | គោលបំណង |
|---|---|
| i. ជួបជាមួយជនរងគ្រោះ និងចាប់ផ្តើមសកម្មភាព | ជួបជាមួយជនរងគ្រោះ (សិស្ស និងបុគ្គលិកសាលា) ដោយការសម្តែងនូវសមានចិត្ត ដោយមិនដាក់បន្ទុកលើពួកគេ និងឆ្លើយតបទៅនឹងសំណូមពររបស់ពួកគេ |
| ii. សុវត្ថិភាព និងសន្តិសុខ | ធានាបាននូវសន្តិសុខភ្លាមៗដើម្បីឱ្យជនរងគ្រោះអាចសម្រាកកាយ និងចិត្ត |
| iii. ស្ថេរកម្ម | បំបាត់វិបល្លាសរបស់ជនរងគ្រោះដែលត្រូវបានសន្ធប់ដោយស្ថានការណ៍ហើយ ផ្តល់ឱ្យពួកគេនូវទស្សនវិស័យ |
| iv. ប្រមូលព័ត៌មាន | ប្រមូលព័ត៌មានពាក់ព័ន្ធ និងកំណត់ពីតម្រូវការ និងបញ្ហាបច្ចុប្បន្នរបស់ជនរងគ្រោះ |
| v. ជួយដោះស្រាយបញ្ហាដែលកើតឡើងជាក់ស្តែង | ជួយជនរងគ្រោះក្នុងការដោះស្រាយតម្រូវការបច្ចុប្បន្នរបស់ពួកគេតាមវិធីជាក់ស្តែង |
| vi. លើកកម្ពស់ទំនាក់ទំនងជាមួយមនុស្សជុំវិញខ្លួន | លើកកម្ពស់ទំនាក់ទំនងរបស់ជនរងគ្រោះជាមួយគ្រួសារ/មិត្តភក្តិ/គ្រូបង្រៀន/បុគ្គលិកសាលាផ្សេងទៀតដែលនៅជិតពួកគេ និងជាមួយអង្គការនៅក្នុងសហគមន៍ និងផ្តល់ជំនួយដើម្បីធ្វើឱ្យទំនាក់ទំនងទាំងនេះមានរយៈពេលយូរ |
| vii. ព័ត៌មានមានប្រយោជន៍ក្នុងការឆ្លើយតបទៅនឹងស្ថានការណ៍ | ផ្តល់ឱ្យជនរងគ្រោះនូវព័ត៌មានអំពីប្រតិកម្មស្ត្រេស និងវិធីដោះស្រាយដើម្បីកាត់បន្ថយការឈឺចាប់របស់ពួកគេ និងបង្កើនមុខងារសម្របសម្រួលរបស់ពួកគេ |
| viii. ការណែនាំ និងការបញ្ជូនបន្ត | ណែនាំសេវាកម្មដែលជនរងគ្រោះត្រូវការនាពេលបច្ចុប្បន្ន ឬនឹងត្រូវការនាពេលអនាគត និងការគាំទ្រការបញ្ជូនបន្ត |

ប្រភព៖ Created using references[2, 14]

**អត្ថបទដកស្រង់ ១៤.៦៖ ប្រតិកម្មខួប (Anniversary reaction)[2]**

*មនុស្សដែលរងរបួសដោយសារគ្រោះមហន្តរាយ ឬឧបទ្ទវហេតុ/គ្រោះថ្នាក់ដែលធ្លាប់ជាសះស្បើយអាចនឹងជួបប្រទះការប៉ះទង្គិចផ្លូវចិត្តម្តងទៀតនៅថ្ងៃដែលពួកគេបានរងគ្រោះ។ នេះហៅថា **ប្រតិកម្មខួប (anniversary reaction)**។*

*វិធីសាស្ត្រមួយដើម្បីដោះស្រាយប្រតិកម្មខួបនេះ គឺជូនដំណឹងដល់អ្នកអាណាព្យាបាល និងកុមារជាមុនថា ប្រតិកម្មពីមុនអាចកើតឡើងសាជាថ្មីនៅពេលកាលបរិច្ឆេទនៃគ្រោះមហន្តរាយ ឬឧបទ្ទវហេតុ/គ្រោះថ្នាក់នោះកាន់តែខិតជិតមកដល់។ ប៉ុន្តែពួកគេមិនបាច់មានការព្រួយបារម្ភទេទោះបីជាវាកើតឡើងវិញក៏ដោយ ពីព្រោះប្រតិកម្មនេះអាចកើតឡើងចំពោះមនុស្សគ្រប់គ្នា។ ការណែនាំបែបនេះ នឹងការពារកុមារមិនឱ្យទទួលរងការរំខាន និងការថប់បារម្ភពីការកើតឡើងនៃប្រតិកម្មខួបនេះក៏ដូចជាដើម្បីឱ្យអ្នកអាណាព្យាបាលឆ្លើយតបដោយស្ងប់ស្ងៀម។*

## ៨ តួនាទីបុគ្គលិកសាលាក្នុងការបង្កើតសាលារៀនប្រកបដោយសុវត្ថិភាព

ផ្នែកនេះពន្យល់ពីតួនាទីចាំបាច់របស់បុគ្គលិកសាលាក្នុងការធានាសុវត្ថិភាព និងរក្សាសន្តិសុខទីកន្លែង/បរិស្ថាន។[8,10] បុគ្គលិកសាលាត្រូវធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ និងចាត់វិធានការទៅតាមកាលៈទេសៈដើម្បីការពារសុវត្ថិភាពអាយុជីវិត និងសុខភាពរាងកាយរបស់សិស្សពីគ្រោះថ្នាក់។ ពួកគេក៏ត្រូវយល់ដឹងឱ្យបានពេញលេញអំពីរចនាសម្ព័ន្ធនៃការរៀបចំនៅក្នុងសាលារៀនក៏ដូចជាសារៈសំខាន់ និងភាពបន្ទាន់នៃសុវត្ថិភាពសាលារៀន និងដើម្បីបង្កើនការយល់ដឹងអំពីសុវត្ថិភាព និងជំនាញឆ្លើយតបសុវត្ថិភាពក៏ដូចជាជំនាញអប់រំសុវត្ថិភាពរបស់ពួកគេ។ ដើម្បីសម្រេចបានកិច្ចការនេះ ចាំបាច់ត្រូវមានការបណ្តុះបណ្តាលជាក់ស្តែងដល់បុគ្គលិកសាលាដើម្បីបំពេញតម្រូវការរបស់សាលារៀន និងសហគមន៍។

ឧទាហរណ៍ ការប្រើប្រាស់ព័ត៌មានសុវត្ថិភាពចុងក្រោយបំផុតដែលផ្តល់ដោយរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការជំនួយអន្តរជាតិ បុគ្គលិកសាលាទាំងអស់ត្រូវប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ដើម្បីធានាសុវត្ថិភាពសិស្ស យល់ពីបញ្ហាចាំបាច់ដើម្បីការពារសុខភាព និងសុវត្ថិភាពសិស្ស និងមានចំណេះដឹង និងជំនាញមូលដ្ឋានលើខ្លឹមសារ និងវិធីសាស្ត្រនៃការបង្រៀន។ ដូច្នេះទាមទារឱ្យមានការកែលម្អការបណ្តុះបណ្តាលស្តីពីសុវត្ថិភាពសាលារៀនសម្រាប់បុគ្គលិកសាលា។ ទាក់ទងនឹងកិច្ចការនេះ រចនាសម្ព័ន្ធនៅក្នុងសាលារៀនក៏ត្រូវកែលម្អផងដែរដើម្បីឱ្យបុគ្គលិកសាលាទាំងអស់អាចចែករំលែកព័ត៌មានចុងក្រោយ។

ឧទាហរណ៍ ការបណ្តុះបណ្តាល និងខ្លឹមសារមានដូចខាងក្រោម។ ទាក់ទងនឹងទម្រង់នៃការបណ្តុះបណ្តាល លំហាត់ធ្វើត្រាប់តាមដែលពិភាក្សាថា តើត្រូវចាត់វិធានការអ្វីខ្លះលើករណីសន្មត់កើតឡើងនៅសាលារៀន និងការបណ្តុះបណ្តាលដោយបុគ្គលិកខាងក្រៅដែលមានជំនាញមានប្រសិទ្ធភាពបន្ថែមលើការឧទ្ទេសតាមថ្នាក់រៀន។

i. ការហ្វឹកហាត់ការជម្លៀសសម្រាប់ការបង្ការគ្រោះមហន្តរាយ/បទល្មើសដោយផ្អែកលើសៀវភៅស្តីពីការគ្រប់គ្រងវិបត្តិ
ii. ហ្វឹកហាត់ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយ/ឧបទ្ទវហេតុ (រួមទាំងការឆ្លើយតបទៅនឹងសិស្ស និងអាណាព្យាបាលដែលរងផលប៉ះពាល់ ឬរងរបួស)
iii. ការជួយសង្គ្រោះចលនាបេះដូងរួមមាន ឧបករណ៍វាស់ចង្វាក់បេះដូងស្វ័យប្រវត្តិ (AED) និងការសង្គ្រោះបឋម
iv. បញ្ហាទាក់ទងនឹងការបង្កើតបរិយាកាសមានសុវត្ថិភាពដោយប្រើស្ថិតិនៃគ្រោះមហន្តរាយ និងគ្រោះថ្នាក់ដែលបានកើតឡើងនៅក្នុងសាលារៀនក៏ដូចជាព័ត៌មានអំពីករណីជាក់លាក់
v. បញ្ហាទាក់ទងនឹងការអប់រំសុវត្ថិភាពរបស់សិស្ស ឧទាហរណ៍ គុណសម្បត្តិ/ជំនាញទាក់ទងនឹងសុវត្ថិភាពដែលត្រូវអភិវឌ្ឍការកំណត់ទីតាំងនៃការអប់រំសុវត្ថិភាព ការយល់ដឹងរួមអំពីខ្លឹមសារ/សម្ភារៈឧបទេស
vi. ការថែទាំសុខភាពផ្លូវចិត្តរបស់សិស្ស បុគ្គលិកសាលា និងអ្នកអាណាព្យាបាល

## ៩ ការអប់រំសុវត្ថិភាពដល់សិស្ស[10]

ដើម្បីធានាសុវត្ថិភាពសិស្ស គឺចាំបាច់ណាស់ត្រូវផ្តល់ការអប់រំអំពីសុវត្ថិភាពឱ្យសិស្សចេះព្យាករណ៍ និងបញ្ចៀសគ្រោះថ្នាក់ពីខ្លួនឯង បន្ថែមពីលើការគ្រប់គ្រងសុវត្ថិភាពយ៉ាងហ្មត់ចត់នូវគ្រឿងបរិក្ខារ/គ្រឿងសង្ហារិមដូចជាការត្រួតពិនិត្យសុវត្ថិភាព។ ដូច្នេះការអប់រំអំពីសុវត្ថិភាពត្រូវបានបញ្ជ្រាបតាមរយៈសកម្មភាពអប់រំទាំងអស់ (គ្រប់មុខវិជ្ជា និងព្រឹត្តិការណ៍សាលារៀន)។

### ៩.១. ការអភិវឌ្ឍសមត្ថភាពដើម្បីព្យាករណ៍ និងចៀសផុតពីគ្រោះថ្នាក់

សិស្សអាចជួបប្រទះគ្រោះថ្នាក់នៅក្នុងស្ថានភាពដែលមានតែសិស្សដូចជា នៅតាមផ្លូវទៅ ឬមកពីសាលារៀន ឬថ្ងៃឈប់សម្រាក។ ក្នុងស្ថានភាពបែបនេះ សិស្សត្រូវព្យាករណ៍ និងចៀសគ្រោះថ្នាក់ដោយខ្លួនឯងដោយកត់សម្គាល់ពីគ្រោះថ្នាក់ដែលអាចកើតមានដោយទស្សន៍ទាយថាគ្រោះថ្នាក់ប្រភេទណាដែលអាចកើតមានឡើង ហើយសម្រេចចិត្ត

ធ្វើអ្វីមួយដើម្បីចៀសគ្រោះថ្នាក់។ ត្រូវផ្តល់ការអប់រំសុវត្ថិភាពដល់សិស្សសាលាដើម្បីអភិវឌ្ឍសមត្ថភាពគិត និងសម្រេចចិត្តដោយខ្លួនឯងបានគ្រប់កាលៈទេសៈ។

ឧទាហរណ៍ វាមានសារៈសំខាន់ណាស់ក្នុង**ការបណ្តុះសមត្ថភាពរបស់សិស្សក្នុងការព្យាករណ៍ និងបញ្ចៀសគ្រោះថ្នាក់ក្នុងហេតុការ**គ្រោះធម្មជាតិក្នុងតំបន់ដូចជា ព្យុះទីហ្វុង ព្យុះត្រូពិច ទឹកជំនន់ និងគ្រោះរាំងស្ងួត ខណៈពេលដែលការប្រើប្រាស់សម្ភារៈដែលបានរៀបចំនៅក្នុងតំបន់នីមួយៗ និងសកម្មភាពពាក់ព័ន្ធ ដើម្បីឱ្យសិស្សគិតពិចារណាអំពីឈុតឆាកជាក់លាក់ក៏ដូចជាសកម្មភាពពិសោធន៍។

## ៩.២. ការប្រើប្រាស់ធនធានមនុស្ស/ធនធានសហគមន៍

ដើម្បីធានាប្រសិទ្ធភាពបន្ថែមទៀតក្នុងការអប់រំសុវត្ថិភាពរបស់សិស្ស គឺចាំបាច់ត្រូវទទួលបានកិច្ចសហប្រតិបត្តិការពីគ្រូឧទ្ទេសនៃអង្គការខាងក្រៅ រួមទាំងអង្គការក្រៅរដ្ឋាភិបាល និងស្នើសុំដល់ប្រជាជន និងសហគមន៍ជួយផ្តល់នូវសម្ភារៈឧបទេស និងឱកាសសិក្សា។ សំខាន់ត្រូវជ្រើសរើស និងពិចារណាលើខ្លឹមសារ និងវិធីសាស្ត្រយោងតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន និងសហគមន៍។ ជាពិសេសនៅសាលារៀនដែលការរៀនសូត្រត្រូវបានអនុវត្តតាមកម្មវិធីសិក្សានៃមុខវិជ្ជានីមួយៗ ពិតជាមានសារៈសំខាន់ក្នុងការប្រើប្រាស់ធនធានមនុស្សខាងក្រៅប្រកបដោយប្រសិទ្ធភាពដោយភ្ជាប់កម្មវិធីសិក្សាតាមមុខវិជ្ជាផ្សេងៗគ្នាជាជាងផ្តល់ឱកាសសិក្សាបែបឯករាជ្យដាច់តែឯង។ នេះគឺជាវិធីសាស្ត្រមួយនៃការគ្រប់គ្រងកម្មវិធីសិក្សា។

ឧទាហរណ៍ កិច្ចសហការជាមួយសហគមន៍រួមបញ្ចូលខ្លឹមសារដូចខាងក្រោម៖

i. ការណែនាំរបស់ប៉ូលីស និងអ្នកជំនាញផ្នែកបង្ការគ្រោះមហន្តរាយ/សុវត្ថិភាពក្នុងការបណ្តុះបណ្តាលសុវត្ថិភាពនៅក្នុងសាលារៀន។
ii. ប្រើធនធានសហគមន៍ និងអង្គការដែលទាក់ទងនឹងសុវត្ថិភាព (ឧទាហរណ៍ គណៈកម្មការឃុំ គ្រប់គ្រងគ្រោះមហន្តរាយ ក្រុមគ្រប់គ្រងគ្រោះមហន្តរាយភូមិ)[16] ជាសម្ភារធនធានបណ្តុះបណ្តាល។
iii. ប្រើឯកសារលេខាសាស្ត្រ ភូមិសាស្ត្រ បរិស្ថាន និងគ្រោះមហន្តរាយកន្លងមក[16] ជាសម្ភារៈឧបទេស។
iv. សិក្សា និងពិសោធន៍ការងាររបស់មនុស្សដែលការពារសុវត្ថិភាពនៅក្នុងសហគមន៍
v. ចូលរួមក្នុងព្រឹត្តិការណ៍សុវត្ថិភាពនៅក្នុងសហគមន៍ដើម្បីអភិវឌ្ឍជំនាញដើម្បីធានាសុវត្ថិភាពផ្ទាល់ខ្លួន (ជួយខ្លួនឯង) និងស្មារតីនៃកិច្ចសហប្រតិបត្តិការ (ការជួយគ្នាទៅវិញទៅមក)។

### អត្ថបទដកស្រង់ ១៤.៧៖ វិធានការទាក់ទងនឹងគ្រាប់មីននៅប្រទេសកម្ពុជា

*នៅក្នុងប្រទេសកម្ពុជាដែលជាបច្ច័យនៃសង្គ្រាមស៊ីវិលដ៏យូរអង្វែង* ***គ្រាប់មីន*** *និង****គ្រាប់មិនទាន់ផ្ទុះ****រាប់លានគ្រាប់នៅតែមិនត្រូវបានបោសសម្អាត។ គេហៅថាជាប្រទេសដែលសម្បូរដោយគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ។ គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះទាំងនេះបានបណ្តាលឱ្យមានការស្លាប់ និងរងរបួសដល់ជនស៊ីវិលមួយចំនួនធំដែលភាគច្រើនជាកុមារដែលបង្កបញ្ហាមនុស្សធម៌យ៉ាងធ្ងន់ធ្ងរ។ នៅតំបន់ជនបទ គ្រាប់មីនគំរាមកំហែងដល់សុវត្ថិភាពរស់នៅប្រចាំថ្ងៃ និងរាំងស្ទះដល់ការអភិវឌ្ឍក្នុងតំបន់ និងការស្តារសេដ្ឋកិច្ចឡើងវិញ។*

*វិធានការប្រឆាំងគ្រាប់មីននៅកម្ពុជាត្រូវបានដឹកនាំដោយមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីននៅកម្ពុជា (CMAC)។ CMAC រាយការណ៍ថា ចំនួនគ្រាប់មីនដែលបានដោះចេញក្នុងកំឡុងពីឆ្នាំ១៩៩២ ដល់ខែមករា ឆ្នាំ២០២០ មានចំនួនលើសពី ៥៤០ ០០០គ្រាប់។[17] មជ្ឈមណ្ឌលនេះអនុវត្តសកម្មភាពដោយបង្កើតផែនការ និងគោលដៅរយៈពេលវែងសម្រាប់បញ្ហាផ្សេងៗរួមមាន ផែនការដោះមីន ការទូទាត់សំណងដល់ជនរងគ្រោះដោយសារគ្រាប់មីន និងការអប់រំអំពីហានិភ័យនៃគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ខណៈពេលដែលទទួលបានការគាំទ្រពីទីភ្នាក់ងារអង្គការសហប្រជាជាតិ ប្រទេសនានា និងអង្គការក្រៅរដ្ឋាភិបាល។ បញ្ហាគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះនៅតែជះឥទ្ធិពលយ៉ាងខ្លាំងដល់សុខភាព និងសុវត្ថិភាពរបស់កុមារ និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា (**សូមមើលជំពូកទី ១៣**)។*

## ☞ លំហាត់សម្រាប់ការគិត និងការស្រាវជ្រាវបន្ថែម

[១៤-១] តើអ្នកអាចលើកឧទាហរណ៍អ្វីខ្លះអំពីលក្ខណៈនៃឧបទ្ទវហេតុ/គ្រោះថ្នាក់ទាក់ទងនឹងកុមារ? ជ្រើសរើសឧទាហរណ៍មួយនៃឧបទ្ទវហេតុ/គ្រោះថ្នាក់នៅកម្ពុជា ហើយពិភាក្សាអំពីកត្តា និងប្រវត្តិនៃការកើតឡើងក៏ដូចជាវិធានការបង្ការ។

[១៤-២] តើមានកន្លែងគ្រោះថ្នាក់ទាំងក្នុង និងជុំវិញសាលារៀនដែរឬទេ? ជ្រើសរើសសាលាបឋមសិក្សាមួយនៅក្បែរនោះហើយបង្កើតផែនទីព្យាករណ៍គ្រោះថ្នាក់ និងតារាងត្រួតពិនិត្យសុវត្ថិភាពសម្រាប់ (១) បរិវេណសាលារៀន និង (២) តំបន់ជុំវិញសាលារៀន។

[១៤-៣] ស៊ើបអង្កេត និងរាយការណ៍អំពីស្ថានភាពជាក់ស្តែងនៅសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យដែលនៅក្បែរនោះថា តើមានប្រព័ន្ធគ្រប់គ្រងវិបត្តិដែរឬទេ តើបានផ្តល់ការអប់រំសុវត្ថិភាព និងតើមានការបណ្តុះបណ្តាលអំពីការជម្លៀសនិងការបណ្តុះបណ្តាលដល់បុគ្គលិកសាលាដែរឬទេ។

## ឯកសារយោង៖


1. Takizawa T (author and editor): [New Edition] Learning School Health from Basics [2nd edition]. Kenpakusha, Tokyo. 2018. [Japanese]
2. Watanabe M (author and editor): School Safety and Crisis Management Revised 3rd Edition. TAISHUKAN Publishing, Tokyo. 2020. [Japanese]
3. Ichimura K, Shimomura Y, Watanabe M: Drug Abuse, Smoking, and Alcohol Consumption Behavior and Normative Consciousness Among Junior and Senior High School Students. Japanese journal of school health 43(1): 39-49. 2001.
4. National Institute of Statistics, Ministry of Planning, Cambodia: Cambodia Demographic and Health Survey 2014. https://dhsprogram.com/pubs/pdf/fr312/fr312.pdf
5. The World Bank: https://data.worldbank.org/indicator/SH.STA.TRAF.P5?end=2019&locations=KH& start=2000&view=chart
6. Ministry of Education, Culture, Sports, Science and Technology: Safety Education in Schools to Nurture “Zest for Living”. 2019. https://www.mext.go.jp/component/a_menu/education/detail/__icsFiles/afieldfile/2019/04/03/1289314_02.pdf
7. Ederer DJ, Bui TV, Parker EM, Roehler DR, Sidik M, et al. Helmets for Kids: evaluation of a school-based helmet intervention in Cambodia. Injury Prevention. 22:52-58, 2016 https://www.ncbi.nlm.nih.gov/pmc/articles/PMC6883409/
8. UNICEF: [Summary] THE STATE OF THE WORLD’S CHILDREN 2017 Children in a digital world. https://www.unicef.org/media/48601/file
9. UNDRR: The human cost of weather-related disasters 1995-2015. https://www.preventionweb.net/files/46796_cop21weatherdisastersreport2015.pdf
10. Ministry of Education, Culture, Sports, Science and Technology: Guide to Compiling Crisis Management Manuals for Schools. Japan Sport Council School Safety Department. 2018. https://www.mext.go.jp/a_menu/kenko/anzen/__icsFiles/afieldfile/2019/05/07/1401870_01.pdf
11. Ministry of Education, Culture, Sports, Science and Technology: School Safety for School Personnel e-learning Basic Training ① Text material https://anzenkyouiku.mext.go.jp/learning/course1-1/pdf/Basic_1.pdf.
12. Ministry of Education, Culture, Sports, Science and Technology: School Safety for School Personnel e-learning Basic Training ② Text material https://anzenkyouiku.mext.go.jp/learning/course1-2/pdf/Basic_2.pdf
13. Brymer M, Taylor M, Escudero P, Jacobs A, Kronenberg M, et al. Psychological first aid for schools: Field operations guide, 2nd Edition. (2012). Los Angeles: National Child Traumatic Stress Network.
14. Tanaka E: How to implement Psychological First Aid for Schools in Japan. Japanese Bulletin of Traumatic Stress Studies Number 14:41-58, 2019.
15. Tajima Y, Shizuoka Prefecture *Yogo* Teachers’ Association. “Crisis Management” addressed by school organizations, Higashiyama Shobo, Tokyo. 2020.
16. Information on Disaster Risk Reduction of the Member Countries. Cambodia, Asian Disaster Reduction Center https://www.adrc.asia/nationinformation.php?NationCode=116&Lang=en&NationNum=06
17. Cambodia Mine Action Center: https://cmac.gov.kh/en/article/progress-summary-report/cmac-s-operational-progress-report-from-992-to-january-2020.html